## មាតិកា

សារលិខិតគាំទ្ររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ........ i
លិខិតថ្លែងអំណរគុណរបស់ឯកឧត្តមបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ........ iii

១- សេចក្តីផ្តើម ........ ១
២- ចក្ខុវិស័យ ........ ៤
៣- បេសកកម្ម ........ ៤
៤- គោលបំណង ........ ៤
៥- គោលដៅ ........ ៥
៦- ក្របខណ្ឌយុទ្ធសាស្ត្រ ........ ៥
ក- ការវិភាគជាយុទ្ធសាស្ត្រ ........ ៥
ខ- ទិសដៅជាយុទ្ធសាស្ត្រ ........ ៧
គ- យុទ្ធសាស្ត្រ ........ ៧
៧- សកម្មភាពការងារ ........ ២៤
៨- ធនធានហិរញ្ញវត្ថុ ........ ៣៨
៩- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ........ ៣៩
១០- សេចក្តីសន្និដ្ឋាន ........ ៤៦

### ឧបសម្ព័ន្ធ

- ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ ........ ៤៧
- លក្ខខណ្ឌចាំបាច់ដើម្បីសំរេចជោគជ័យក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់ ........ ៤៨

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

## នៃព្រះរាជាណាចក្រកម្ពុជា

## គាំទ្រ ផែនការយុទ្ធសាស្ត្រជាតិ លុបបំបាត់ជំងឺគ្រុនចាញ់

## នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១-២០២៥

ជាកិត្តិយសបំផុត សម្រាប់រូបខ្ញុំ ក្នុងការផ្តល់សារលិខិត ទៅកាន់ជនរួមជាតិយើងទាំងអស់គ្នា ស្តីពីឯកសារផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១-២០២៥ ក្នុងគោលដៅធានានូវប្រទេសកម្ពុជាមួយគ្មានជំងឺគ្រុនចាញ់ ។

ជំងឺគ្រុនចាញ់នៅតែជាបញ្ហាសុខភាពសាធារណៈ និងជាបន្ទុកសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសារតែអត្រាឈឺ និងអត្រាស្លាប់ដោយសារជំងឺគ្រុនចាញ់ នៅមានចំនួនច្រើននៅឡើយ។ ផែនការយុទ្ធសាស្ត្រជាតិនេះជាសមិទ្ធផលថ្មីមួយទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលស្របទៅនឹងគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានរូបខ្ញុំជានាយករដ្ឋមន្ត្រី ក្នុងការលើកកំពស់សុខុមាលភាពរបស់ប្រជាជន និងដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១-២០២៥ បានរៀបចំឡើងស្របគ្នាជាមួយនឹងការអំពាវនាវរបស់អង្គការសុខភាពពិភពលោក និងអង្គការអន្តរជាតិនានា ក្នុងការលុបបំបាត់ជាសកលជំងឺគ្រុនចាញ់នៅឆ្នាំ២០៣០។ រាជរដ្ឋាភិបាលកម្ពុជា រួមសហការជាមួយបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ ទាំងក្នុង និងក្រៅប្រទេស ប្តេជ្ញាជំរុញការលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យអស់នៅឆ្នាំ២០២៥ ដើម្បីធានាថាជំងឺគ្រុនចាញ់លែងជាបញ្ហា

សុខភាពសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ផែនការយុទ្ធសាស្ត្រជាតិនេះ គឺជាឯកសារយោងដ៏សំខាន់ ដែលចង្អុលបង្ហាញនូវផ្លូវដើរច្បាស់លាស់ជាដំណាក់ៗ និងគោលដៅកំណត់ជាក់លាក់ហើយ ធានាបាននូវគោលដៅជាចុងក្រោយ គឺប្រទេសកម្ពុជាមួយដែលគ្មានជំងឺគ្រុនចាញ់។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារទាំងអស់ដែលបានខិតខំរៀបចំ បង្កើតជាផែនការយុទ្ធសាស្ត្រជាតិនេះឡើង ដែលរួមមានក្រសួងសុខាភិបាល អន្តរក្រសួងជាពិសេស ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានដឹកនាំអង្គប្រជុំត្រួតពិនិត្យចុងក្រោយត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងដៃគូអភិវឌ្ឍន៍ទាំងអស់ ធ្វើឲ្យឯកសារនៃផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១-២០២៥ បានលេចចេញជារូបរាងហើយត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ជាឯកសារមានតម្លៃបំផុតសម្រាប់ជាតិយើង និងពិភពលោកទាំងមូល។ ខ្ញុំសូមអំពាវនាវដល់ក្រសួងសុខាភិបាល និងគ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធទាំងអស់ រួមទាំងដៃគូអភិវឌ្ឍន៍ មានអង្គការជាតិ និងអន្តរជាតិ ក៏ដូចជាសហគមន៍ទាំងមូលត្រូវចូលរួមនិងគាំទ្រឲ្យបានខ្លាំងក្លាដើម្បីឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ទទួលបានជោគជ័យ តាមការគ្រោងទុក។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ភាគគីពាក់ពន្ធ័ទាំងអស់ ទាំងក្នុងជួររាជរដ្ឋាភិបាល និងទាំងដៃគូអភិវឌ្ឍន៍នឹងយកផែនការយុទ្ធសាស្ត្រជាតិនេះ ទៅប្រើប្រាស់ជាត្រីវិស័យ សម្រាប់ការអនុវត្តឲ្យមានប្រសិទ្ធភាព។ ខ្ញុំត្រៀមជាស្រេចដើម្បីសហការជាមួយភាគីពាក់ពន្ធ័ទាំងអស់ ក្នុងការប្រែក្លាយព្រះរាជាណាចក្រកម្ពុជាឲ្យទៅជាប្រទេសមួយគ្មានជំងឺគ្រុនចាញ់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីថ្លែងអំណរគុណ

## របស់ឯករដ្ឋមន្ត្រីក្រសួងសុខាភិបាល

ខ្ញុំមានកិត្តិយសដ៏ថ្លៃថ្លា ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសុខាភិបាល បានរៀបចំឯកសារផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១-២០២៥។ នៅក្នុងតួនាទីនេះ ខ្ញុំមានភ័ព្វសំណាងពិសេសដោយបានទទួលការគាំទ្រយ៉ាងពេញទំហឹងពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពីមន្ត្រីសុខាភិបាលរបស់ខ្ញុំ ដែលប្រកបដោយសមត្ថភាព ឆន្ទៈ និងភាពស្វាហាប់ ជាពិសេសកិច្ចសហការប្រកបដោយផ្លែផ្កាជាមួយអន្តរក្រសួង ស្ថាប័ន ក្រោមកិច្ចសម្របសម្រួលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បានធ្វើឲ្យផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១-២០២៥ ត្រូវបានអនុម័តគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា។

ដោយយល់យ៉ាងច្បាស់ពីផលប៉ះពាល់អវិជ្ជមាននៃជំងឺគ្រុនចាញ់សម្រាប់ប្រទេសកម្ពុជា ក៏ដូចជាសម្រាប់ពិភពលោក រាជរដ្ឋាភិបាលកម្ពុជា និងបណ្តាដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិទាំងអស់ បានប្រមើលមើលនូវយុទ្ធសាស្ត្រគន្លឹះនានា វិភាគអំពីលទ្ធភាពនៃធនធានក្នុងការអនុវត្តនូវយុទ្ធសាស្ត្រទាំងនោះ តាមរយៈការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ពន្ធ័ទាំងអស់ សំដៅធ្វើយ៉ាងណាកាត់បន្ថយអត្រាឈឺ និងស្លាប់ជាបណ្តើរៗ និងឈានទៅរកការលុបបំបាត់ទាំងស្រុងជំងឺគ្រុនចាញ់ក្នុងព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០២៥ ។ ការខិតខំប្រឹងប្រែងទាំងនេះ គឺជាការចូលរួមចំណែកមួយយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកំពស់សុខុមាលភាពរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចេរភាព ។

ក្រសួងសុខាភិបាលប្តេជ្ញាបំពេញការងារជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១-២០២៥ ឲ្យមាន

ប្រសិទ្ធភាព និងសម្រេចបានជោគជ័យទៅតាមគោលដៅដែលបានកំណត់ ។ ខ្ញុំមានសុទិដ្ឋិនិយមចំពោះការគាំទ្រ និងកិច្ចសហប្រតិបត្តការពីបណ្តាក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិជាដៃគូអភិវឌ្ឍន៍ទាំងអស់ ធានាដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ឲ្យដំណើរការទៅដោយរលូន និងទទួលបានលទ្ធផលដូចការរំពឹងទុក។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជានិច្ចជាកាលសម្តេចតេជោតែងតែយកចិត្តទុកដាក់ដល់សុខភាព និងសេចក្តីសុខរបស់ប្រជាជន ហើយតែងតែគាំទ្រ និងផ្តល់អាទិភាពដល់វិស័យសុខាភិបាលជានិច្ច។ ជាសក្ខីភាពពេលនេះ សម្តេចតេជោបានផ្តល់អនុសាសន៍ណែនាំ និងគាំទ្រយ៉ាងខ្លាំងក្លាដល់ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជា-ណាចក្រកម្ពុជា ឆ្នាំ២០១១-២០២៥ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួង ស្ថាប័ន និងបណ្តាផ្នែកពាក់ព័ន្ធទាំងអស់ ព្រមទាំងអង្គការជាតិ និងអន្តរជាតិជាដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានចូលរួមរៀបចំផែនការយុទ្ធសាស្ត្រជាតិនេះ ជាពិសេសទីស្តីការគណៈរដ្ឋមន្ត្រី ។ យើងប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការឲ្យកាន់តែរលូនថែមទៀត នៅក្រោមកិច្ចដឹកនាំរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចឲ្យបានជោគជ័យ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១-២០២៥ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ២០១១

វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង

# ១- សេចក្តីផ្តើម

## សារបទ្ធាន

ជំងឺគ្រុនចាញ់នៅតែជាបញ្ហាសុខភាពសាធារណៈនិងជាបន្ទុកសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសារតែអត្រាឈឺនៃជំងឺគ្រុនចាញ់ក្នុងចំណោមប្រជាជន ១០០០ នាក់ មានចំនួន ៦,១៦ នាក់ ហើយករណីស្លាប់ដោយជំងឺគ្រុនចាញ់នៅមានចំនួនច្រើននៅឡើយគឺមានអ្នកស្លាប់ចំនួន ២៧៩នាក់ ក្នុងឆ្នាំ២០០៩ យោងតាមឯកសារមូលនិធិសកលជុំទី៩ដែលបានអនុម័តរួចហើយ ( រូបភាពទី១ និង ទី២ )។ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា និងផ្តល់អាទិភាពយ៉ាងខ្ពស់ដល់ការទប់ស្កាត់ជំងឺនេះជាពិសេស ក្រសួងសុខាភិបាលបានអនុញ្ញាតឲ្យស្ថាបន័ជំនាញគឺ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្រ្ត និងបាណកសាស្រ្ត (ម.គ.ច) រៀបចំ និងអនុវត្តយុទ្ធសាស្រ្តប្រយុទ្ធនឹងជំងឺគ្រុនចាញ់នៅទូទាំងប្រទេស។

ទោះបីជាមានការថយចុះករណីគ្រុនចាញ់ដែលបានធ្វើរោគវិនិច្ឆ័យគ្លីនិក និងព្យាបាល រួមទាំងអត្រាស្លាប់ក្នុងចំណោមអ្នកជំងឺធ្ងន់ធ្ងរ ក្នុងរយៈពេល១៣ឆ្នាំចុងក្រោយនេះក៏ដោយ (របាយការណ៍គ្រុនចាញ់ឆ្នាំ២០០០-២០០៩) ក៏ការឈឺ និងការស្លាប់ដោយសារជំងឺគ្រុនចាញ់នៅកម្ពុជានៅតែមានកម្រិតខ្ពស់បើប្រៀបធៀបនឹងបណ្តាប្រទេសផ្សេងៗក្នុងតំបន់។

បញ្ហាជំងឺគ្រុនចាញ់ក្នុងប្រទេសកម្ពុជាជាកត្តាដ៏សំខាន់មួយដែលរួមចំណែកធ្វើឲ្យមានបញ្ហាភាពស្លេកស្លាំង ផលលំបាកពេលមានផ្ទៃពោះ ទារកមិនគ្រប់ទំងន់ និងការលូតលាស់ខ្សោយសម្រាប់កុមារ។ ជំងឺគ្រុនចាញ់នៅកម្ពុជាធ្វើឲ្យប៉ះពាល់ដល់ការចំណាយសេដ្ឋកិច្ច រួមបញ្ចូលទាំងចំណាយផ្ទាល់លើការព្យាបាលជំងឺពិសេសចំពោះជនក្រីក្រ និងជនដែលងាយរងគ្រោះ ព្រមទាំងការចំណាយសង្គមផ្សេងៗទៀត ដូចជា ការបាត់បង់ពេលវេលាសិក្សារបស់កុមារ និងយុវវ័យ ពេលវេលាប្រកបមុខរបរ ការធ្វើដំណើរនិងបំលាស់ទី និងការសន្សំប្រាក់កាសទុកជាដើម។ ផលប៉ះពាល់នៃបញ្ហាជំងឺគ្រុនចាញ់ក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច រាប់បញ្ចូលទាំងការងារពាណិជ្ជកម្ម ទេសចរណ៍ និងការងារវិនិយោគផ្ទាល់ពីបរទេស និងក្នុងស្រុក។

ការធ្លាក់ចុះនៃករណីជំងឺគ្រុនចាញ់ (ប្រហែល ៩.៧ភាគរយក្នុង១ឆ្នាំ) និងករណីស្លាប់ (ប្រហែល ៨.៤ភាគរយក្នុង១ឆ្នាំ) គឺបានមកដោយសារកត្តាជាច្រើន រួមមានកត្តាសន្តិភាព ស្ថេរភាពនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ច និងការរីកចំរើនខាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងព័ត៌មាន ការផ្លាស់ប្តូរមុខរបរ ការកែលំអបរិស្ថាន ឥរិយាបថរស់នៅ និងសំខាន់គឺភាពប្រសើរឡើងនៃការទទួលយកបាននូវអន្តរាគមន៍នៃការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់ តាមរយៈការកែលំអនូវសេវាពិនិត្យព្យាបាល និងការបង្ការការចម្លងដោយមានការត្រួតពិនិត្យនិងតាមដានរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់នៃក្រសួងសុខាភិបាល និងអង្គភាពក្រោមឱវាទរបស់ក្រសួងសុខាភិបាល និងដៃគូទាំងឡាយ ដែលរួមមាន នាយកដ្ឋានសុខាភិបាល និងនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចនៃក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកិច្ចការនារី អាជ្ញាធរមូលដ្ឋាន និងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ រួមជាមួយនិងការធ្វើវិមជ្ឈការ និងការពង្រីកនូវសកម្មភាពជាគន្លឹះនៃកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់រហូត

ដល់តំបន់ជនបទដាច់ស្រយ៉ាលដែលជាកន្លែងពិបាកស្វែងរកសេវាសុខភាព តាមរយៈគំនិតផ្តួចផ្តើមឲ្យមានអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ ការផ្លាស់ប្តូរឥរិយាបថ និងការប្រាស្រ័យទាក់ទង ការបង្កើននូវអត្រាគ្របដណ្តប់ការចែកចាយមុងដល់ប្រជាជនប្រឈមនឹងការចម្លង និងការកែលំអសេវាធ្វើរោគវិនិច្ឆ័យ និងព្យាបាលគ្រុនចាញ់នៅតាមសេវាសុខាភិបាលសាធារណៈ។ល។

ទោះជាយ៉ាងដូច្នេះ របកគំហើញថ្មីៗពីគម្រោងដែលគាំទ្រដោយមូលនិធិប៊ីលហ្គេត និងការសិក្សាជាច្រើន បានបង្ហាញឲ្យឃើញថា មេរោគគ្រុនចាញ់ដែលធន់នឹងឱសថប្រឆាំងជំងឺគ្រុនចាញ់ ផ្សំដោយសារធាតុអាតេមីស៊ីនីនកំពុងមានវត្តមាននៅតាមបណ្តោយព្រំដែនកម្ពុជា ថៃ អាចនឹងវិវត្តទៅជាមេរោគដែលស៊ាំជាមួយថ្នាំអាតេមីស៊ីនីន ជាប្រភេទថ្នាំដែលត្រូវបានណែនាំថាមានប្រសិទ្ធភាពខ្ពស់បំផុត ក្នុងការព្យាបាលជំងឺគ្រុនចាញ់ប្រភេទហ្វាល់ស៊ីប៉ារ៉ូម។

ការសាយភាយនៃមេរោគគ្រុនចាញ់ដែលស៊ាំជាមួយថ្នាំអាតេមីស៊ីនីន គឺជាដំណើរថយក្រោយនៃការខិតខំប្រឹងប្រែងរបស់ពិភពលោក ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺគ្រុនចាញ់ ព្រោះថាបច្ចុប្បន្ននេះនៅពុំទាន់មានឱសថប្រឆាំងនឹងជំងឺគ្រុនចាញ់ណាដែលមានប្រសិទ្ធភាពស្មើនិងថ្នាំអាតេមីស៊ីនីននៅឡើយទេ។

ព្រះរាជាណាចក្រកម្ពុជាបានឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងបញ្ហាដ៏ស្រួចស្រាវនេះដោយរៀបចំបង្កើតនូវយុទ្ធសាស្ត្រគ្រប់គ្រងជំងឺគ្រុនចាញ់រយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយមានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដូចជាអង្គការសុខភាពពិភពលោក និងទទួលបានជំនួយឧបត្ថម្ភពីមូលនិធិប៊ីលហ្គេត និងមូលនិធិសកល សម្រាប់អនុវត្តន៍យុទ្ធសាស្ត្រខាងលើ។ ថវិកាជាង ១០០ លានដុល្លារអាមេរិក បានត្រូវអនុម័តដោយមូលនិធិសកល ជុំទី៩ សម្រាប់គម្រោងឆ្ពោះទៅកាន់ដំណាក់កាលត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់ ពីឆ្នាំ២០១០ ដល់២០១៥។ ការជំរុញលើកទឹកចិត្តពីរាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ការអភិវឌ្ឍន៍ទាំងឡាយ ដូចជាការរីកចំរើនផ្នែកសង្គម សេដ្ឋកិច្ច ការរីកចំរើននៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការសិក្សាអប់រំ ការអភិវឌ្ឍធនធានមនុស្ស។ល។ ដែលផ្តល់ដល់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ នូវកម្លាំងចិត្តដ៏មុតមាំសម្រាប់ការប្រមើលមើលនូវផ្លូវដើរវែងឆ្ងាយក្នុងការធ្វើឲ្យប្រទេសជាតិទាំងមូលចាកផុតអំពីបញ្ហាជំងឺគ្រុនចាញ់ក្នុងអំឡុងពេលមួយទស្សវត្សរ៍កន្លះខាងមុខ។

គោលដៅចម្បងនៃផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ២០១១ ដល់ ២០២៥ ត្រូវបានរៀបចំឡើងដើម្បីធានាថា មេរោគគ្រុនចាញ់ដែលស៊ាំនឹងថ្នាំអាតេមីស៊ីនីនត្រូវបានលុបបំបាត់នៅត្រឹមឆ្នាំ២០១៥ ហើយធានាថាកម្ពុជានឹងធ្វើដំណើរឆ្ពោះទៅរកការលុបបំបាត់ជំងឺគ្រុនចាញ់បង្កឡើងដោយមេរោគប្រភេទហ្វាល់ស៊ីប៉ារ៉ូម ព្រមទាំងធានាមិនឲ្យមានការស្លាប់ដោយជំងឺគ្រុនចាញ់នៅឆ្នាំ២០២០ និងឆ្ពោះទៅរកការលុបបំបាត់មេរោគគ្រុនចាញ់ប្រភេទវីវ៉ាក់នៅឆ្នាំ២០២៥។ ការផ្តួចផ្តើមគំនិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្របគ្នាជាមួយនិងការអំពាវនាវដ៏ខ្លាំងក្លាឲ្យមានការលុបបំបាត់ជាសកលជំងឺគ្រុនចាញ់ ពីសំណាក់អង្គការសម្របសម្រួលប្រយុទ្ធនឹងជំងឺគ្រុនចាញ់ អង្គការសុខភាពពិភពលោក និងអង្គការអន្តរជាតិផ្សេងៗទៀត។

រូបភាព ទី ១: ចំនួនករណីគ្រុនចាញ់ទាំងអស់ ដែលបានព្យាបាល

ចំនួនករណីគ្រុនចាញ់ធ្ងន់ធ្ងរ និងករណីស្លាប់ ពីឆ្នាំ២000-២0១0




រូបភាពទី ២: និន្នាការនៃការស្លាប់ដោយជំងឺគ្រុនចាញ់ ចាប់ពីឆ្នាំ១៩៩៧-២០២០




និន្នាការមរណភាពដែលបានកត់ត្រាក្នុងប្រជាជន១០០.០០០នាក់ តាមយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់ (២០១១-២០២០)

មរណភាពក្នុងប្រជាជន ១០០.០០០នាក់ មាននិន្នាការថយចុះ ៣.៩ %ប្រចាំឆ្នាំ (តាមទិន្នន័យពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៧)

មរណភាពក្នុងប្រជាជន ១០០.០០០នាក់ មាននិន្នាការថយចុះ ៧.៥ %ប្រចាំឆ្នាំ (តាមទិន្នន័យពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៤)

មរណភាពក្នុងប្រជាជន ១០០.០០០នាក់ មាននិន្នាការថយចុះ ៨.៤ %ប្រចាំឆ្នាំ (តាមទិន្នន័យពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧)

ប្រភព៖ ផ្នែកអេពីដេមីសាស្ត្រ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ឆ្នាំ២០០៩

## ២- ចក្ខុវិស័យ

ចក្ខុវិស័យយូរអង្វែងរបស់រាជរដ្ឋាភិបាលគឺ ប្រទេសកម្ពុជាមួយដែលគ្មានជំងឺគ្រុនចាញ់។ នៅឆ្នាំ២០១៥ គោលដៅសហស្សវត្សរ៍នៃការគ្រប់គ្រងជំងឺគ្រុនចាញ់នឹងសម្រេចបាន បញ្ហាជំងឺគ្រុនចាញ់នឹងលែងជាមូលហេតុចម្បងនៃការស្លាប់ ហើយនិងពុំមែនជាឧបសគ្គនៃការរីកចំរើន ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមសម្រាប់កម្ពុជាទៀតឡើយ។ ប្រជាជនទាំងអស់ទទួលបាននូវសេវាការពារ និងព្យាបាលជំងឺគ្រុនចាញ់ទូលំទូលាយជាមួយនិងការបំបាត់ទាំងស្រុងមេរោគគ្រុនចាញ់ដែលមានភាពស៊ាំជាមួយឱសថដែលផ្សំជាមួយប្រភេទថ្នាំអាតេមីស៊ីនីន។ ចាប់ពី ឆ្នាំ២០១៥ តទៅ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍តាំងចិត្តបន្តជួយគាំទ្រ ទាំងផ្នែកនយោបាយ បច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងធានាបាននូវការលុបបំបាត់ជំងឺគ្រុនចាញ់ជាបណ្តើរៗតាមតំបន់នៅឆ្នាំ២០២០ និងការលុបបំបាត់ទាំងស្រុងជំងឺគ្រុនចាញ់នៅឆ្នាំ២០២៥។

## ៣- បេសកកម្ម

បេសកកម្មរបស់រាជរដ្ឋាភិបាលគឺការធ្វើការរួមគ្នាជាមួយផ្នែកពាក់ព័ន្ធទាំងអស់ ពិសេសការចូលរួមរបស់សហគមន៍ផ្ទាល់ ដើម្បីធានានូវការផ្តល់សេវាប្រកបដោយនិរន្តរភាព ពោលគឺសេវាបង្ការ និងព្យាបាលដែលមានប្រសិទ្ធភាពសម្រាប់ជនដែលប្រឈមខ្លាំងជាមួយជំងឺគ្រុនចាញ់តាមរយៈការចលនាធនធានដែលជាតម្រូវការចាំបាច់ ព្រមទាំងធានាបាននូវការប្រកាន់ខ្ជាប់ការអនុវត្តតាមមគ្គុទ្ទេសក៍ណែនាំគំរូរបស់ជាតិសម្រាប់អន្តរាគមន៍ជាគន្លឹះនានា ក្នុងការប្រយុទ្ធនឹងជំងឺគ្រុនចាញ់។

បេសកកម្មជាគន្លឹះដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់មានដូចតទៅ:

- ទប់ស្កាត់ការចម្លងជំងឺគ្រុនចាញ់ ដោយការប្រើប្រាស់មុងជ្រលក់ថ្នាំ
- ផ្តល់សេវាទូលំទូលាយ ដោយធ្វើរោគវិនិច្ឆ័យរហ័ស និងព្យាបាលទាន់ពេលវេលា ដោយឥតគិតថ្លៃ ក្នុងសេវាសាធារណៈ
- បញ្ឈប់ការសាយភាយនៃភាពស៊ាំរបស់មេរោគគ្រុនចាញ់ជាមួយនឹងឱសថគ្រុនចាញ់
- ត្រួតពិនិត្យការលក់ឱសថគ្រុនចាញ់ក្លែងក្លាយក្នុងទីផ្សារ ដោយសហការល្អជាមួយសេវាឯកជន
- យុទ្ធនាការព្យាបាលជំងឺគ្រុនចាញ់ជាសមូហភាពក្នុងសហគមន៍
- អភិវឌ្ឍន៍ផែនការប្រតិបត្តិ បច្ចេកទេស ដោយសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធ ជាអន្តរវិស័យទាំងក្នុង និងក្រៅប្រទេសដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់។

## ៤- គោលបំណង

១. លុបបំបាត់មេរោគគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូម ដែលស៊ាំនឹងថ្នាំអាតេមីស៊ីនីន

២. លុបបំបាត់ជំងឺគ្រុនចាញ់ដោយផ្តោតជាសំខាន់ដំបូងទៅលើមេរោគគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូម និងធានាមិនឲ្យមានករណីស្លាប់ដោយសារជំងឺគ្រុនចាញ់

៣. លុបបំបាត់ជំងឺគ្រុនចាញ់ទាំងស្រុងលើគ្រប់ទម្រង់នៃមេរោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ៥- គោលដៅ

- **រយៈពេលខ្លី (ត្រឹមឆ្នាំ២០១៥)** ៖ ដើម្បីឆ្ពោះទៅរកការ*ត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់* នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ក្នុងការលប់បំបាត់មេរោគគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូម ដែលស៊ាំនឹងថ្នាំអាតេមីស៊ីនីន។
- **រយៈពេលមធ្យម (ត្រឹមឆ្នាំ២០២០)** ៖ ដើម្បីឆ្ពោះទៅរក*ការលុបបំបាត់ជំងឺគ្រុនចាញ់* នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតជាសំខាន់ដំបូងទៅលើមេរោគគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូម និងធានាមិនឲ្យមានករណីស្លាប់ដោយជំងឺគ្រុនចាញ់។
- **រយៈពេលវែង (ត្រឹមឆ្នាំ២០២៥)** ៖ ដើម្បីសម្រេចឲ្យបាន*ដំណាក់កាលលុបបំបាត់ជំងឺគ្រុនចាញ់ទាំងស្រុង* នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើគ្រប់ទម្រង់នៃមេរោគគ្រុនចាញ់។

# ៦- ក្របខណ្ឌយុទ្ធសាស្ត្រ

## ក- ការវិភាគជាយុទ្ធសាស្ត្រ

### ក.១ បញ្ហាប្រឈម និងឧបសគ្គ ដែលជួបប្រទះក្នុងកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់

ទោះជាមានសមិទ្ធិផលដ៏ច្រើនដែលគួរឲ្យកត់សំគាល់ ក្នុងរយៈពេលខ្លីបែបនេះក៏ដោយ ក៏ក្រសួងសុខាភិបាល កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បាននិងកំពុងជួបប្រទះនូវបញ្ហាប្រឈម និងឧបសគ្គមួយផ្នែក ដែលកើតមានឡើងស្របគ្នា។ បញ្ហាទាំងនោះរួមមានៈ

- ធនធានមានកម្រិត ទាំងធនធានមនុស្ស និងថវិកា
- ការយឺតយ៉ាវក្នុងការផ្គត់ផ្គង់មុងជ្រលក់ថ្នាំនៅពេលខ្លះដែលដៃគូអភិវឌ្ឍន៍ផ្តល់ឲ្យ
- ការត្រួតពិនិត្យឱសថក្លែងក្លាយ និងគ្លីនិកឯកជននៅខ្វះចន្លោះ
- ការយល់ដឹងរបស់ប្រជាជន និងឥរិយាបថប្រឈមនឹងជំងឺគ្រុនចាញ់ក៏មានកម្រិត
- ការធ្វើដំណើរនៅរដូវភ្លៀងមានការលំបាកហើយជារដូវមានការចម្លងគ្រុនចាញ់ខ្ពស់ ជាពិសេសនៅតាមតំបន់ ព្រៃភ្នំដែលមានប្រជាជនភាគតិចរស់នៅ
- ចលនាប្រជាជន ការធ្វើចំណាកស្រុកចល័តទៅកាន់តំបន់ដែលមានការចម្លងមានការលំបាកគ្រប់គ្រង
- ភាពស្មុគស្មាញនៃលក្ខណៈរូបសាស្ត្រ ជីវសាស្ត្ររបស់ភ្នាក់ងារចម្លងជំងឺ និងវត្តមាននៃមេរោគដែលបង្កជាជំងឺធ្ងន់ធ្ងរ គំរាមកំហែងដល់ជិវិត ភាពស៊ាំជាមួយថ្នាំគ្រុនចាញ់នៃពពួកហ្វាល់ស៊ីប៉ារ៉ូម និងការសាយភាយ។ ការបង្កឲ្យមានការលាប់ជំងឺឡើងវិញនៃពពួកមេរោគវីវ៉ាក់ បញ្ហាកង្វះG6PD។ល។ ធ្វើឲ្យមានការលំបាកក្នុងការព្យាបាលផ្តាច់ឫសជំងឺគ្រុនចាញ់
- ការធ្វើសកម្មភាពប្រយុទ្ធនឹងជំងឺគ្រុនចាញ់ពឹងផ្អែកភាគច្រើនលើធនធានពីខាងក្រៅ ដែលអាចជាកង្វល់ដល់និរន្តរភាពនៃការខិតខំប្រឹងប្រែងប្រយុទ្ធ និងលុបបំបាត់ជំងឺគ្រុនចាញ់។

ក្រសួងសុខាភិបាលមានចក្ខុវិស័យប្រកបដោយសុទិដ្ឋិនិយមថា បញ្ហាប្រឈម និងឧបសគ្គទាំងអស់នេះនឹងអាចជំនះបានតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០១១-២០២៥។

## ក.២ យុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់

ផែនការយុទ្ធសាស្ត្រសុខាភិបាល បានដោះស្រាយនូវរាល់ចំណុចខ្វះខាតនៃសេវាសុខភាពទាំងអស់ ដែលកំណត់ដោយក្រសួងសុខាភិបាល (MoH) កន្លងមកដោយផ្អែកលើកម្រិតអាទិភាពនៃបញ្ហា ជាមួយនឹងពេលវេលាខុសៗគ្នា។ ដើម្បីបង្កើននូវលទ្ធផលនៃការគ្រប់គ្រងជំងឺគ្រុនចាញ់ រាល់ចំណុចខ្សោយនៃប្រព័ន្ធសុខាភិបាលត្រូវតែកែលំអស្របទៅតាមសកម្មភាពជាក់លាក់នៃការគ្រប់គ្រងជំងឺ។ ចម្លើយយតបជាក់លាក់នៃជំងឺ ចំពោះការអភិវឌ្ឍប្រព័ន្ធសុខាភិបាល គឺបង្ហាញនៅក្នុងយុទ្ធសាស្ត្រទាំងមូល ដែលត្រូវកាត់បន្ថយជាមួយគ្នា និងការពង្រឹងប្រពន្ធ័សុខាភិបាលជាទូទៅ។ កិច្ចប្រឹងប្រែងខាងក្រោមបានត្រូវអនុវត្តដើម្បីធានាថាផលវិបាកទាំងឡាយនឹងត្រូវបានបញ្ចៀស ក្នុងខណៈពេលនៃការអនុវត្តយុទ្ធសាស្ត្រនៃការលុបបំបាត់ជំងឺគ្រុនចាញ់:

- ដោយអ្នកស្ម័គ្រចិត្តភូមិព្យាបាលជំងឺគ្រុនចាញ់ជាផ្នែកមួយនៃបណ្តាញក្រុមគាំទ្រសុខភាពភូមិ ជាឱកាសដែលអាចធ្វើឲ្យការពង្រីកបន្ថែមនូវសេវាកម្មវិធីគ្រុនចាញ់តាមរយៈអ្នកស្ម័គ្រចិត្តក្នុងសហគមន៍ មានលក្ខណៈងាយស្រួល ដូចគ្នានឹងបទអន្តរាគមន៍សម្រាប់ការរស់រាននៃកុមារ (គ្រប់គ្រងជំងឺផ្លូវដង្ហើម ជំងឺរាគ) ការអនុវត្តដូតស៍ចំពោះកម្មវិធីរបេងសហគមន៍ ការថែទាំអ្នកផ្ទុកមេរោគអេដស៍ជាដើម។
- បណ្តុះបណ្តាលមន្ត្រីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ក្នុងការពង្រឹងច្បាប់ការត្រួតពិនិត្យគុណភាពឱសថទូទៅ ព្រមទាំងឱសថព្យាបាលជំងឺគ្រុនចាញ់ផងដែរ។
- ការធ្វើវិមជ្ឈការនៃការទទួលខុសត្រូវលើការគ្រប់គ្រង និងការអភិបាលទូលំទូលាយ ដោយមិនសំដៅដោយឡែកត្រឹមតែបុគ្គលិកផ្តល់សេវាគ្រុនចាញ់តែប៉ុណ្ណោះទេ។
- ការប្រតិបត្តិការងារភ្ជាប់នឹងរង្វាន់លើកទឹកចិត្តមិនត្រូវកំណត់ចំពោះតែបុគ្គលិកមណ្ឌលសុខភាព ដែលធ្វើការឲ្យកម្មវិធីគ្រុនចាញ់ទេប៉ុន្តែត្រូវអនុវត្តសម្រាប់ការកែលំអសេវាកម្មមូលដ្ឋានទាំងមូល។ ឧទាហរណ៍: រង្វាន់លើកទឹកចិត្តនឹងត្រូវបានផ្តល់ឲ្យសម្រាប់ការផ្តល់សេវាកម្មសុខភាព ពេញ២៤ម៉ោងលើ ២៤ម៉ោង។
- ការបង្កើនឡើងនៃសកម្មភាពតាមព្រំដែន និងការសម្របសម្រួលការឆ្លងដែនអាចនឹងត្រូវចាប់ផ្តើមជាមួយនឹងការផ្តោតទៅលើជំងឺគ្រុនចាញ់ដំបូង ហើយនិងក្តីសង្ឃឹមនៃការពង្រីកបន្ថែមរួមបញ្ចូលបញ្ហាសុខភាពតាមព្រំដែនផ្សេងទៀត ដូចជា ជំងឺអេដស៍ និងរបេង។
- បទពិសោធន៍ភាពជោគជ័យនៃកិច្ចសហការគ្នារវាងវិស័យឯកជន និងរដ្ឋក្នុងកម្មវិធីគ្រុនចាញ់នឹងត្រូវចែករំលែកជាមួយកម្មវិធីផ្សេងៗ។
- ការស្រាវជ្រាវប្រតិបត្តិ និងការត្រួតពិនិត្យតាមដាន វាយតម្លៃ និងបង្កើនការប្រើប្រាស់ទិន្នន័យដែលមានស្រាប់ផ្តល់សារៈប្រយោជន៍ដល់ការគ្រប់គ្រងជារួម (ដូចជា ការអង្កេតស្រាវជ្រាវពីមូលដ្ឋានសុខាភិបាល ការសិក្សាពីគ្រួសារ និងការសិក្សាពីសហគមន៍)។
- បង្កើនទំនាក់ទំនងរវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងឃ្លាំងឱសថកណ្តាលដើម្បីជួយធ្វើឲ្យប្រសើរឡើងនូវបណ្តាញនៃប្រព័ន្ធផ្គត់ផ្គង់ឱសថ និងប្រព័ន្ធព័ត៌មានសម្រាប់ជំងឺផ្សេងៗទៀត។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់នឹងធ្វើការជាមួយការិយាល័យទទួលជំនួយផ្ទាល់ពីមូលនិធិសកលទាំងអស់ (ជាអាទិ៍ MoH, NCHADS និងCENAT) និងឃ្លាំងឱសថកណ្តាលដើម្បីអនុវត្តការវាយតម្លៃពីលក្ខខណ្ឌនៃការស្តុកឱសថ សម្ភារៈ បង្កើត និងអនុវត្តនូវផែនការរក្សាទុកឱសថ សម្ភារៈឲ្យបានប្រសើរ។

## ខ- ទិសដៅជាយុទ្ធសាស្ត្រ

ក្រសួងសុខាភិបាលមានបំណងទប់ស្កាត់និងលុបបំបាត់ជំងឺគ្រុនចាញ់តាមរយៈការអនុវត្តនូវយុទ្ធសាស្ត្ររយៈពេលវែង ដូចខាងក្រោម ៖

១. ធានានូវការគ្របដណ្តប់បានទាំងស្រុង (១០០ភាគរយ) ការធ្វើរោគវិនិច្ឆ័យជំងឺគ្រុនចាញ់ឲ្យបានឆាប់រហ័ស និងការព្យាបាលទាន់ពេលវេលា និងមានប្រសិទ្ធភាព នូវគ្រប់ករណីជំងឺគ្រុនចាញ់ និងការសម្លាប់ហ្គាម៉េតនៃមេរោគប្លាស់ស៊ីប៉ារ៉ូម (គោលដៅលើប្រជាជនចំណុចរួមទាំងប្រជាជនចល័ត និងជនចំណាកស្រុក)។

២. បញ្ឈប់នូវការប្រើប្រាស់ឱសថដែលនាំឲ្យមានភាពស៊ាំរបស់មេរោគគ្រុនចាញ់ជាមួយថ្នាំអាតេមីស៊ីនីន តាមរយៈការធ្វើឲ្យប្រសើរឡើងនូវការទទួលយកសេវាព្យាបាលជំងឺបានត្រឹមត្រូវ និងបង្ការការប្រើប្រាស់ថ្នាំគ្រុនចាញ់តែមួយមុខ និងថ្នាំខុសច្បាប់ ឬក្លែងក្លាយនៅតាមសេវាសុខភាពសាធារណៈ និងឯកជន។

៣. ធានាបាននូវការទទួលយកសេវាបង្ការ ជាពិសេសការបង្ការការចម្លងមេរោគគ្រុនចាញ់ដែលមានភាពស៊ាំនឹងថ្នាំអាតេមីស៊ីនីន ក្នុងចំណោមប្រជាជនគោលដៅ តាមរយៈការត្រួតពិនិត្យសត្វមូស ដែលជាភ្នាក់ងារចម្លងជំងឺ និងមធ្យោបាយការពារដោយខ្លួនឯងផ្ទាល់ និងការកែលំអបរិស្ថាន។

៤. ធានាថាសហគមន៍បានទទួលការយល់ដឹងទូលំទូលាយអំពីជំងឺគ្រុនចាញ់ និងការប្រកាន់យកឥរិយាបថត្រឹមត្រូវក្នុងការបង្ការការចម្លងជំងឺគ្រុនចាញ់ ចលនាសហគមន៍ និងការគាំទ្រកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់។

៥. គ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាពរួមបញ្ចូលទាំងប្រពន្ធ័ព័ត៌មានសុខាភិបាល និងការតាមដាន ព្រមទាំងការសម្របសម្រួលនានាដែលនឹងនាំឲ្យការអនុវត្តយុទ្ធសាស្ត្រនៃការលុបបំបាត់ជំងឺគ្រុនចាញ់ មានគុណភាពខ្ពស់ និងទទួលបានជោគជ័យ។

## គ- យុទ្ធសាស្ត្រ

នៅក្នុងតារាងខាងក្រោមបានបង្ហាញលំអិតនូវទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗ ៥ យុទ្ធសាស្ត្រ ៣៩ និងសកម្មភាពជាគន្លឹះ ១៧៧ ដែលត្រូវអនុវត្ត ដើម្បីធានាឲ្យបានជោគជ័យនូវគោលដៅលុបបំបាត់ជំងឺគ្រុនចាញ់នៅត្រឹមឆ្នាំ២០២៥។

**ទិសដៅជាយុទ្ធសាស្ត្រ យុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះដែលត្រូវអនុវត្តន៍**

| ទិសដៅជាយុទ្ធសាស្ត្រ យុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ |
|---|---|
| **<u>ទិសដៅជាយុទ្ធសាស្ត្រទី១</u>**: ធានានូវការគ្របដណ្តប់បានទាំងស្រុង (១០០ភាគរយ) ការធ្វើរោគវិនិច្ឆ័យជំងឺគ្រុនចាញ់ឲ្យបានឆាប់រហ័ស និងការព្យាបាលទាន់ពេលវេលា និងមានប្រសិទ្ធភាពនូវគ្រប់ករណីជំងឺគ្រុនចាញ់ និងការសម្លាប់ហ្គាម៉េតនៃមេរោគប្លាស់ស៊ីប៉ារ៉ូម (ផ្តោតគោលដៅលើប្រជាជនចំណុច រួមទាំងប្រជាជនចល័ត និងជនចំណាកស្រុក)។ | |
| **១.១. ធ្វើការពិនិត្យយ៉ាងទៀងទាត់ កែលំអ បើមានការចាំបាច់នូវមគ្គុទ្ទេសក៍ព្យាបាលជំងឺគ្រុនចាញ់ដោយផ្អែកលើភស្តុតាងដែលសមស្រប ក្នុងគោលបំណងលុបបំបាត់ជំងឺគ្រុនចាញ់។** | |

| | |
|---|---|
| ១.១.១. ធ្វើសិក្ខាសាលាស្តីពីគោលនយោបាយថ្នាក់ជាតិនៃឱសថគ្រុនចាញ់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.១.២. កែលំអ និងផ្សព្វផ្សាយមគ្គុទ្ទេសក៍ព្យាបាលជំងឺគ្រុនចាញ់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក |
| **១.២. ធ្វើឲ្យប្រសើរឡើងនូវកម្មវិធីសិក្សាស្តីពីការធ្វើរោគវិនិច្ឆ័យ និងព្យាបាលទាន់ពេល** | |
| ១.២.១. កែលំអនិងធ្វើឲ្យប្រសើរឡើងនូវកម្មវិធីសិក្សាស្តីពីការធ្វើរោគវិនិច្ឆ័យ និងព្យាបាល | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| **១.៣. ធានាឲ្យមានការធ្វើរោគវិនិច្ឆ័យទាន់ពេល ដើម្បីធ្វើការព្យាបាល ដោយមិនគិតថ្លៃនៅគ្រប់សេវាសុខភាពសាធារណៈ: អ្នកស្ម័គ្រចិត្តព្យាបាល ជំងឺគ្រុនចាញ់ភូមិ អ្នកស្ម័គ្រចិត្តចល័តព្យាបាលជំងឺគ្រុនចាញ់ភូមិ (រួមទាំងកងកម្លាំងយោធា និងកងកម្លាំងនគរបាល) នៅត្រឹមឆ្នាំ២០១២** | |
| ១.៣.១. ផ្តល់ការអប់រំសុខភាព កែប្រែទំលាប់ ដើម្បីជំរុញការធ្វើរោគវិនិច្ឆ័យដល់អ្នកប្រើប្រាស់ និងអ្នកផ្តល់សេវា | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.៣.២. បង្រៀនអ្នកផ្តល់សេវាពីការធ្វើរោគវិនិច្ឆ័យទាន់ពេល និងត្រឹមត្រូវ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.៣.៣. ធ្វើឲ្យកាន់តែប្រសើរឡើងមគ្គុទ្ទេសក៍ព្យាបាលជំងឺគ្រុនចាញ់ ដោយណែនាំឲ្យធ្វើរោគវិនិច្ឆ័យមុនព្យាបាលឲ្យបាន ១០០ភាគរយ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក |
| **១.៤. ធានាឲ្យមានការធ្វើរោគវិនិច្ឆ័យដោយមីក្រូទស្សន៍ឲ្យបាន ១០០ ភាគរយ នៅសេវាសុខាភិបាលសាធារណៈ:** (រួមទាំងកងកម្លាំងយោធា និង កងកម្លាំងនគរបាល)ត្រឹមឆ្នាំ ២០២០ (ដោយមិនរាប់បញ្ចូលអ្នកស្ម័គ្រចិត្ត ព្យាបាលជំងឺគ្រុនចាញ់ភូមិ) និងលើកលែងក្នុងករណីដាច់ចរន្តអគ្គិសនីសេវាពេលយប់ជាដើម | |
| ១.៤.១. កែលំអហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល (ដូចជាការផ្តល់ថាមពលអគ្គិសនី ) | ក្រសួងសុខាភិបាល |
| ១.៤.២. ហ្វឹកហ្វឺនជំនាញបុគ្គលិកមីក្រូទស្សន៍ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.៤.៣. ធានារ៉ាប់រងគុណភាពមន្ទីរពិសោធន៍ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.៤.៤. ដំណើរការធ្វើពិសោធន៍តេស្ត G6PD | |
| ១.៤.៥. ធានាការផ្គត់ផ្គង់ជាប្រចាំ សម្ភារៈ បរិក្ខារគ្រុនចាញ់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់និងឃ្លាំងឱសថកណ្តាល |

| | |
|---|---|
| ១.៤.៦. ធ្វើការតាមដាន និងអភិបាល | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| **១.៥. ពង្រឹង និងកែលំអគុណភាពសេវាធ្វើរោគវិនិច្ឆ័យ** | |
| ១.៥.១. បង្រៀនដល់សេវាសាធារណៈទាំងអស់ ជាពិសេសថ្នាក់មណ្ឌលសុខភាព និងធ្វើការតាមដានការអនុវត្ត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.៥.២. ធ្វើការតាមដាន និងផ្តល់ដំបូន្មានដល់សេវាសាធារណៈទាំងអស់ ជាពិសេសថ្នាក់មណ្ឌលសុខភាព | |
| ១.៥.៣. បង្រៀនអ្នកផ្តល់សេវាឯកជន និងធ្វើការតាមដានការអនុវត្ត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.៥.៤. ធ្វើការតាមដាន និងផ្តល់ដំបូន្មានដល់អ្នកផ្តល់សេវាឯកជន | |
| ១.៥.៥. ពង្រឹងសមត្ថភាពធ្វើរោគវិនិច្ឆ័យសេវាសាធារណៈដោយផ្តល់ជូនសម្ភារៈចាំបាច់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.៥.៦. អនុវត្តការធានារ៉ាប់រងគុណភាពមីក្រូទស្សន៍ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.៥.៧. អនុវត្តការតាមដានដ៏មានគុណភាព ស្តីពីការប្រើប្រាស់តេស្តរហ័សនៅសេវាសាធារណៈ និងសេវាឯកជន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| **១.៦. លើកកំពស់ការព្យាបាលករណីជំងឺគ្រុនចាញ់ ក្នុងសេវាសុខភាពសាធារណៈ រាល់ករណីជំងឺគ្រុនចាញ់ត្រូវបានព្យាបាលដោយថ្នាំរួមផ្សំជាមួយសារធាតុអាតេមីស៊ីនីន និងបូកបន្ថែមថ្នាំសម្លាប់ហ្គាម៉ែត ត្រឹម ឆ្នាំ២០១១ ក្នុងសេវាសុខភាពសាធារណៈ (រួមទាំងកងកម្លាំងយោធា និងកងកម្លាំងនគរបាល) ព្រមទាំងសេវាឯកជន និងសេវាសហគមន៍** | |
| ១.៦.១. បង្រៀនអ្នកផ្តល់សេវាសាធារណៈ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.៦.២. បង្រៀនគ្រូពេទ្យជ្រើសរើសមកពីមន្ទីរពេទ្យ ស្តីពីករណីដែលបណ្តាលឲ្យស្លាប់នៃករណីគ្រុនចាញ់ធ្ងន់ធ្ងរ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.៦.៣. ស្វែងរក និងធ្វើលទ្ធកម្មថ្នាំគ្រុនចាញ់ដែលមានធាតុផ្សំជាមួយសារធាតុអាតេមីស៊ីនីន សម្រាប់ប្រទេសកម្ពុជា | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.៦.៤. ដំណើរការប្រើប្រាស់ថ្នាំ Primaquine ដោយយោងទៅតាមការសិក្សាស្រាវជ្រាវ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក |
| ១.៦.៥. ធានាផ្គត់ផ្គង់ជាប្រចាំថ្នាំគ្រុនចាញ់ដល់សេវាសុខភាពសាធារណៈ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់និងឃ្លាំងឱសថកណ្តាល |

| | |
|---|---|
| ១.៦.៦. ផ្តល់ការព្យាបាលជំងឺគ្រុនចាញ់មានប្រសិទ្ធភាពដោយបូកបញ្ចូលការសម្លាប់ទម្រង់ហ្កាម៉ែត្ររបស់មេរោគ ហ្វាល់ស៊ីប៉ារ៉ូម នៅក្នុងសេវាសុខភាពសាធារណៈ និងសហគមន៍។ រាល់អ្នកផ្តល់សេវាទាំងអស់ត្រូវតែគោរពតាមមគ្គុទ្ទេសក៍ព្យាបាលជំងឺគ្រុនចាញ់ថ្នាក់ជាតិ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.៦.៧. ធានានូវនិរន្តភាពការងារក្នុងមណ្ឌលសុខភាពតំបន់ទី១ ធ្វើឲ្យប្រសើរឡើងនិរន្តភាពការងារក្នុងមណ្ឌលសុខភាពតំបន់២ និងដំណើរការឲ្យមានបុគ្គលិកប្រចាំការព្យាបាលជំងឺគ្រុនចាញ់នៅក្នុងរាល់មណ្ឌលសុខភាពដែលមានអត្រាចម្លងជំងឺគ្រុនចាញ់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| **១.៧. កែលំអការគ្រប់គ្រងទិន្នន័យគ្រុនចាញ់ និងការផ្តល់របាយការណ៍គ្រុនចាញ់ដោយសេវាឯកជនស្របច្បាប់តាមរយៈគម្រោង** AMFm 2011-15 | |
| ១.៧.១. កែសម្រួល បង្កើត និងអនុវត្តន៍ទំនាក់ទំនងការព្យាបាលរហ័ស | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.៧.២. បង្រៀនអ្នកផ្តល់សេវាឯកជន | |
| ១.៧.៣. អភិបាលគាំទ្រការតាមដានចំពោះអ្នកបំរើសេវាឯកជន | |
| ១.៧.៤. ពង្រឹងការអនុវត្តច្បាប់ស្តីពីការលុបបំបាត់អ្នកផ្តល់សេវាឯកជនមិនស្របច្បាប់ ពង្រឹងការហាមឃាត់ការប្រើប្រាស់ឱសថអាតេមីស៊ីនីនតែមួយមុខ ហាមឃាត់ឱសថក្លែងក្លាយ និងឱសថខ្វះគុណភាព | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿង សំអាង មន្ត្រីនគរបាលយុត្តិធម៌ |
| ១.៧.៥. គាំទ្រ តាមដានវាយតម្លៃចំពោះអ្នកផ្តល់សេវាឯកជន។ ធ្វើការហ្វឹកហ្វឺនស្តីពីការធ្វើរោគវិនិច្ឆ័យជំងឺ ការបញ្ជូនជំងឺ និងការប្រើប្រាស់ឱសថដល់អ្នកផ្តល់សេវាឯកជន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| **១.៨. កម្រិតការធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺគ្រុនចាញ់តែនៅក្នុង សេវាឯកជនដែលគោរពទៅតាមលក្ខខណ្ឌរបស់ក្រសួងសុខាភិបាល (២០១៦-២០២០+)** | |
| ១.៨.១. ជំរុញឲ្យមានការរាយការណ៍ករណីគ្រុនចាញ់ក្នុងសេវាឯកជន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.៨.២. ដំណើរការសកម្មភាពគន្លឹះដែលមានចែងនៅក្នុងចំណុចទី១.៧ ចំពោះសេវាឯកជនមួយចំនួន | |
| **១.៩. ជំរុញសេវាបញ្ជូនជំងឺគ្រុនចាញ់ទាំងក្នុងសេវាសាធារណៈ និងសេវា ឯកជនៈ ត្រូវបញ្ជូនអ្នកជំងឺគ្រុនចាញ់ដែលមានអាយុក្រោម ៥ឆ្នាំ អ្នក ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឲ្យបានទាន់ពេលវេលាទៅសេវាសាធារណៈ ដែលសមស្របទៅតាមកម្រិតជំងឺ** | |

| | |
|---|---|
| ១.៩.១. កែលំអប្រព័ន្ធបញ្ជូនជំងឺ និងការព្យាបាលមុនបញ្ជូន ចំពោះករណី គ្រុនចាញ់ធ្ងន់ធ្ងរដែលនៅដាច់ស្រយាល | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ និងដៃគូ |
| ១.៩.២. កែលំអឲ្យមានគុណភាពនូវសេវាបញ្ជូនជំងឺដែលផ្តល់ដោយមន្ទីរពេទ្យ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់និងដៃគូរួមជាមួយ នាយកមន្ទីរពេទ្យ |
| ១.៩.៣. ដំណើរការឲ្យមានប្រាក់ឥណទានសម្រាប់ការធ្វើដំណើរ ចំពោះការបញ្ជូនអ្នកជំងឺគ្រុនចាញ់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ និងដៃគូ |
| **១.១០. ពង្រឹងការរកករណីគ្រុនចាញ់ក្នុងកំឡុងពេលមានផ្ទៃពោះ** | |
| ១.១០.១. អនុវត្តន៍ការរកករណីគ្រុនចាញ់ចំពោះស្ត្រីមុនពេល សំរាលកូននៅថ្នាក់មណ្ឌលសុខភាព | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ |
| **១.១១. ជំរុញការធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺគ្រុនចាញ់នៅថ្នាក់ សហគមន៍ដោយពង្រីកសេវាអ្នកស្ម័គ្រចិត្តព្យាបាលជំងឺ គ្រុនចាញ់តាមភូមិៈបង្កើតឲ្យមានអ្នកស្ម័គ្រចិត្តព្យាបាលជំងឺ គ្រុនចាញ់តាមភូមិនៅភូមិដែលមានចំងាយលើសពី៥គីឡូម៉ែត្រ ពីមណ្ឌលសុខភាព** | |
| ១.១១.១. រកភូមិដែលមានទីតាំងចំងាយលើសពី៥គីឡូម៉ែត្រពី មណ្ឌលសុខភាពនៅក្នុងតំបន់ដែលមានការចម្លងគ្រុនចាញ់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព |
| ១.១១.២. ជ្រើសរើសអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាម ភូមិ ពីរនាក់ក្នុងមួយភូមិនៅភូមិដែលរកថ្មី | |
| ១.១១.៣. កែសម្រួលកម្មវិធីបណ្តុះបណ្តាលស្តីពីការធ្វើរោគ វិនិច្ឆ័យ និងព្យាបាល | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ និងដៃគូ |
| ១.១១.៤. បណ្តុះបណ្តាល និងបណ្តុះបណ្តាលឡើងវិញ អ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិ អ្នកស្ម័គ្រចិត្តចល័ត ព្យាបាលជំងឺគ្រុនចាញ់តាម ភូមិនៅក្នុងកម្រិតសហគមន៍ ព្រមទាំងតាមដានការអនុវត្ត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព |
| ១.១១.៥. ធ្វើការតាមដានការប្រើប្រាស់តេស្តរហ័សរបស់ អ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ អ្នកស្ម័គ្រចិត្តចល័ត ព្យាបាល ជំងឺគ្រុនចាញ់តាមភូមិ | |
| ១.១១.៦. បណ្តុះបណ្តាល និងបណ្តុះបណ្តាលឡើងវិញ អ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិ អ្នកស្ម័គ្រចិត្តចល័ត ព្យាបាលជំងឺគ្រុនចាញ់ភូមិរួមទាំងសមាជិកដែលទើបរើសថ្មី | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ និងដៃគូ |
| ១.១១.៧. ធានាផ្តល់សម្ភារៈ និងការផ្តល់យោបល់ជាប្រចាំ ដល់អ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ | |

| | |
|---|---|
| ១.១១.៨. បង្កើនការគ្របដណ្តប់ការផ្តល់សេវាព្យាបាលតាមរយៈ អ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិបច្ចុប្បន្ន និងពង្រីកបន្ថែមនូវតំបន់ផ្សេងទៀត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.១១.៩. កែលំអប្រព័ន្ធបញ្ជូនជំងឺចំពោះករណីគ្រុនចាញ់ធ្ងន់ធ្ងរពីភូមិដាច់ស្រយាលទៅមណ្ឌលសុខភាព | |
| ១.១១.១០. រក្សា និងពង្រីកបន្ថែមការរុករកករណីគ្រុនចាញ់ចំពោះស្ត្រីមុនសំរាលកូននៅក្នុងសហគមន៍ | |
| **១.១២. កែលំអការគ្រប់គ្រងករណីគ្រុនចាញ់នៅសេវាព្យាបាលរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ** | |
| ១.១២.១.ធ្វើការបណ្តុះបណ្តាលអ្នកផ្តល់សេវាសុខាភិបាលរបស់កងកម្លាំងយោធា និងកងកម្លាំងនគរបាល | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់រួមជាមួយនាយកដ្ឋានសុខាភិបាលរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ |
| ១.១២.២. ធានាផ្គត់ផ្គង់ជាប្រចាំសម្ភារៈធ្វើរោគវិនិច្ឆ័យ និងថ្នាំព្យាបាលគ្រុនចាញ់ | |
| **១.១៣. បង្កើនការប្រឹងប្រែងខ្ពស់ក្នុងការផ្តល់សេវាធ្វើរោគវិនិច្ឆ័យ និងព្យាបាលរហ័សដោយមិនគិតថ្លៃចំពោះប្រជាជនចំណាកស្រុកតាមរយៈអ្នកស្ម័គ្រចិត្តចល័តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ** | |
| ១.១៣.១. គាំទ្រក្រុមព្យាបាលចល័តរបស់មណ្ឌលសុខភាពដើម្បីអាចផ្តល់សេវាព្យាបាលដល់ក្រុមប្រជាជនចល័ត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.១៣.២. ធ្វើរោគវិនិច្ឆ័យ និងព្យាបាលដល់ប្រជាជនចល័តតាមរយៈ អ្នកស្ម័គ្រចិត្តចល័តព្យាបាលជំងឺគ្រុនចាញ់ដែលបានជ្រើសរើសចេញពីប្រជាជនចល័តដែលស្នាក់នៅយូរ និងរួមបញ្ចូលទាំងសកម្មភាពស្រាវជ្រាវករណីគ្រុនចាញ់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| **១.១៤. លើកកំពស់សកម្មភាពគ្រប់គ្រងជំងឺគ្រុនចាញ់នៅតាមបណ្តោយ ព្រំដែន** | |
| ១.១៤.១. កំណត់តំបន់គ្រុនចាញ់ដើម្បីបង្កើតនូវប៉ុស្តិ៍គ្រុនចាញ់តាមបណ្តោយព្រំដែន តំបន់គ្រុនចាញ់ខ្ពស់(ចំនួនប៉ុស្តិ៍គ្រុនចាញ់) | មជ្ឈមណ្ឌលជាតិប្រយុទ្ធជនឹងជំងឺគ្រុនចាញ់ |
| ១.១៤.២. បង្កើនសេវាការធ្វើរោគវិនិច្ឆ័យរហ័ស និងព្យាបាលទាន់ពេលវេលាពីថ្នាក់សហគមន៍ទៅប្រជាជនដែលឆ្លងកាត់ព្រំដែន | |
| ១.១៤.៣. ផ្តល់ការធ្វើរោគវិនិច្ឆ័យរហ័ស និងព្យាបាលទាន់ពេលវេលា និង សេវាលើកកំពស់សុខភាពនៅកន្លែងត្រួតពិនិត្យតាមព្រំដែន | |

| | |
|---|---|
| **១.១៥. ពង្រឹងនូវប្រព័ន្ធព័ត៌មាន និងប្រព័ន្ធស្រាវជ្រាវដើម្បីរុករកករណីគ្រុនចាញ់ទាំងអស់ និងធានានូវការព្យាបាលប្រកបដោយប្រសិទ្ធភាព** | |
| ១.១៥.១. ធ្វើការស្រាវជ្រាវយ៉ាងសកម្មចំពោះករណីវិជ្ជមានមេរោគគ្រុនចាញ់នៅថ្ងៃទី៣ (រកថ្ងៃទី៧ និងថ្ងៃទី២១ ផងដែរ បើសិនជាចាំបាច់) | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ១.១៥.២. ធ្វើការស្រាវជ្រាវសកម្មករណីនៅថ្នាក់សហគមន៍ | |
| **១.១៦. ពង្រឹងការតាមដានភាពស៊ាំ នឹងថ្នាំគ្រុនចាញ់ និងសកម្មភាពស្រាវជ្រាវ** | |
| ១.១៦.១. បន្តពង្រឹងការតាមដានជាប្រចាំនូវភាពស៊ាំមេរោគទៅនឹងថ្នាំគ្រុនចាញ់ រួមទាំងមេរោគវីវ៉ាក់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ១.១៦.២. អនុវត្តការស្រាវជ្រាវ | |
| ១.១៦.៣. អនុវត្តគម្រោង FSAT | |
| ១.១៦.៤. អនុវត្តគម្រោង MDA | |
| ១.១៦.៥. បង្កើត និងអនុវត្តយុទ្ធសាស្រ្តឲ្យបានត្រឹមត្រូវដើម្បីឆ្លើយតបទៅនឹងកង្វះ G6PD ដើម្បីព្យាបាលឲ្យជាដាច់ចំពោះជំងឺគ្រុនចាញ់បង្កដោយពពួកវីវ៉ាក់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក |

<u>**ទិសដៅជាយុទ្ធសាស្រ្តទី២**</u>: បញ្ឈប់នូវការប្រើប្រាស់ឱសថដែលនាំឲ្យមានភាពស៊ាំរបស់មេរោគគ្រុនចាញ់ជាមួយថ្នាំអាតេមីស៊ីនីន តាមរយៈការធ្វើឲ្យប្រសើរឡើងនូវការទទួលយកសេវាព្យាបាលជំងឺបានត្រឹមត្រូវ និងបង្ការការប្រើប្រាស់ថ្នាំគ្រុនចាញ់តែមួយមុខ និងថ្នាំខុសច្បាប់ ឬក្លែងក្លាយនៅតាមសេវាសុខភាពសាធារណៈនិងឯកជន។

| | |
|---|---|
| **២.១. គាំទ្រ និងពង្រឹងខ្សែចង្វាក់ផ្គត់ផ្គង់សម្រាប់ការធ្វើរោគវិនិច្ឆ័យគ្រុនចាញ់ និងព្យាបាលទាំងនៅក្នុងសេវាសាធារណៈ និងសេវាឯកជន** | |
| ២.១.១. ពង្រឹងប្រព័ន្ធព័ត៌មានសុខាភិបាល និងភ្ជាប់ទៅនឹងប្រព័ន្ធត្រួតពិនិត្យការស្នើសុំ និងការប្រើប្រាស់ឱសថរបស់ស្រុកប្រតិបត្តិ ដើម្បីកែលំអការព្យាករណ៍តម្រូវការឱសថឲ្យបានត្រឹមត្រូវ | នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ២.១.២. កែលំអឃ្លាំងទុកដាក់ឱសថនៅថ្នាក់ខេត្ត ថ្នាក់ស្រុកប្រតិបត្តិ និងថ្នាក់មណ្ឌលសុខភាព | |

| | |
|---|---|
| ២.១.៣. ធ្វើលទ្ធកម្មឱសថគ្រុនចាញ់ និងតេស្តរហ័ស ដែលមានគុណភាពល្អ និងត្រឹមត្រូវដើម្បីផ្តល់ឲ្យសេវាសាធារណៈ និងឯកជនប្រើប្រាស់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ២.១.៤. ផលិតកញ្ចប់ថ្នាំដោយដាក់ការណែនាំជាភាសាទៅតាមតំបន់សម្រាប់សេវាឯកជន | |
| ២.១.៥. រៀបចំ និងប្រើប្រព័ន្ធផ្គត់ផ្គង់ត្រឹមត្រូវដើម្បីធានានូវការផ្គត់ផ្គង់ឲ្យបានគ្រប់គ្រាន់សម្រាប់ការធ្វើតេស្ត និងព្យាបាល | |
| ២.១.៦. ធ្វើលទ្ធកម្ម និងផ្គត់ផ្គង់ប្រអប់គ្រជាក់ដល់ផ្នែកសេវាឯកជនដែលបានទទួលស្គាល់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ២.១.៧. ពង្រឹងខ្សែចង្វាក់ផ្គត់ផ្គង់សម្រាប់ការធ្វើរោគវិនិច្ឆ័យគ្រុនចាញ់ និងព្យាបាលនៅផ្នែកសេវាឯកជន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ២.១.៧.១. បណ្តុះបណ្តាលអ្នកនាំឱសថចូល និងអ្នកលក់ដុំ | |
| ២.១.៧.២. បង្កើតទីផ្សារគោលដៅលក់រាយ (ដំណាក់កាលទី១) | |
| ២.១.៧.៣. អនុវត្តនូវការផ្គត់ផ្គង់ឱសថឲ្យបានគ្រប់គ្រាន់នៅកន្លែងគោលដៅលក់រាយ (ដំណាក់កាលទី២) | |
| ២.១.៧.៤. អនុវត្តការផ្សព្វផ្សាយជាបន្ទាន់ (ដំណាក់កាលទី៣) | |
| **២.២. កែលំអគុណភាពនៃថ្នាំគ្រុនចាញ់ និងហាមមិនឲ្យមានការព្យាបាលគ្រុនចាញ់ដោយថ្នាំតែមួយមុខ និងថ្នាំដែលមិនត្រឹមត្រូវតាមបទដ្ឋានទាំងនៅក្នុងផ្នែកសាធារណៈ និងផ្នែកឯកជន** | |
| ២.២.១. ពិនិត្យ កែសម្រួល និងអនុវត្តបទដ្ឋានច្បាប់ និងគោលនយោបាយណែនាំស្តីអំពីឱសថគ្រុនចាញ់ | |
| ២.២.១.១. ត្រួតពិនិត្យ អធិការកិច្ចឱសថនៅតាមខេត្ត និងស្រុក | នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ២.២.១.២. បណ្តុះបណ្តាលអធិការកិច្ចឱសថថ្នាក់ខេត្ត និងស្រុក | នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង រួមជាមួយអង្គការសុខភាពពិភពលោក |
| ២.២.១.៣. ត្រួតពិនិត្យកន្លែងលក់ឱសថឯកជន | នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ២.២.១.៤. បញ្ឈប់ការនាំចូលឱសថព្យាបាលគ្រុនចាញ់តែមួយមុខតាមផ្លូវគោក | នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងជាមួយ នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច |
| ២.២.១.៥. គាំទ្រសកម្មភាពសមស្របក្នុងករណីដែលឱសថ | |

| | |
|---|---|
| គ្រុនចាញ់មិនត្រឹមត្រូវតាមបទដ្ឋាន ឬឱសថគ្រុនចាញ់ក្លែងក្លាយត្រូវបានរកឃើញដោយរួមបញ្ចូលទាំងការពង្រឹងច្បាប់ | |
| ២.២.២. រក្សានូវប្រព័ន្ធតាមដានវាយតម្លៃទីផ្សារប្រកបដោយប្រសិទ្ធភាព ចំពោះថ្នាំគ្រុនចាញ់ក្រោយពេលធ្វើចរាចរណ៍ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ២.២.៣. ផ្តល់នូវការធានាគុណភាពឱសថគ្រុនចាញ់នៅក្នុងផ្នែកសេវាឯកជន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូរួមជាមួយ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ២.២.៣.១. ប្រមូលសំណាកឱសថគ្រុនចាញ់ពីផ្នែកសាធារណៈ និងផ្នែកឯកជន | មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល |
| ២.២.៣.២. អនុវត្តនូវការពិនិត្យគុណភាពឱសថគ្រុនចាញ់ដែលប្រមូលបានពីផ្នែកសាធារណៈ និងផ្នែកឯកជន | |
| ២.២.៤. រក្សាប្រព័ន្ធតាមដានប្រតិកម្មឱសថ | ការិយាល័យឱសថសារវន្ត ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក និងអង្គការដៃគូ |
| ២.២.៤.១. ពង្រឹងការត្រួតពិនិត្យ Pharmacovigilance | ការិយាល័យឱសថសារវន្ត ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក |
| ២.២.៤.២. បណ្តុះបណ្តាលបុគ្គលិកអំពី Pharmacovigilance | ការិយាល័យឱសថសារវន្ត |
| ២.២.៤.៣. បង្កើនសកម្មភាព Pharmacovigilance ទៅដល់អ្នកផ្តល់សេវាផ្នែកសាធារណៈ និងផ្នែកឯកជន | |
| ២.២.៤.៤. ប្រមូលទិន្នន័យជំងឺពីអ្នកផ្តល់សេវាផ្នែកសាធារណៈ និងផ្នែកឯកជន | អង្គការដៃគូសហការជាមួយការិយាល័យឱសថសារវន្ត |
| ២.២.៤.៥. គ្រប់គ្រងទិន្នន័យ Pharmacovigilance | ការិយាល័យឱសថសារវន្ត និងដៃគូ |
| ២.២.៤.៦. ទំនាក់ទំនង និងផ្តល់ព័ត៌មានត្រលប់ដល់អ្នកផ្តល់សេវា និងអ្នកលក់ឱសថ | |
| ២.២.៥. ដំណើការគណៈកម្មការថ្នាក់ខេត្តលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ | |
| ២.២.៦. បង្កើត និងផ្តល់សម្ភារៈអប់រំស្តីអំពីឱសថក្លែងក្លាយទៅដល់អ្នកផ្តល់សេវា និងដល់សាធារណៈជន | |
| **២.៣.កែលំអការប្រើប្រាស់ឱសថគ្រុនចាញ់ឲ្យបានសមស្រប** | |
| ២.៣.១. បណ្តុះបណ្តាលអ្នកផ្តល់សេវាសាធារណៈ និងផ្នែកឯកជន អំពីការប្រើប្រាសឱសថឲ្យបានត្រឹមត្រូវរួមបញ្ចូលទាំងការក សម្រួលទៅលើកម្មវិធីបណ្តុះបណ្តាល | នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |

| | |
|---|---|
| ២.៣.២. ត្រួតពិនិត្យការអនុវត្តរបស់អ្នកផ្តល់សេវាផ្នែកសាធារណៈ និងផ្នែកឯកជនដោយសហការជាមួយមន្ទីរសុខាភិបាលខេត្ត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| **២.៤. បង្កើនសកម្មភាពគ្រប់គ្រងជំងឺគ្រុនចាញ់នៅក្នុងខេត្តតាមព្រំដែនភាគខាងលិច** | |
| ២.៤.១. អនុវត្តការប្រជុំនៅតាមព្រំដែនឲ្យបានទៀងទាត់ដើម្បីចែក រំលែកព័ត៌មាន និងដើម្បីបង្កើតយុទ្ធសាស្រ្តគ្រប់គ្រងជំងឺគ្រុនចាញ់ រួមគ្នា | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| **២.៥. ពង្រីកយុទ្ធសាស្រ្តចម្រុះផ្នែកសេវាសាធារណៈ និងផ្នែកឯកជន តាមរយៈការសម្របសម្រួល និង ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព** | |
| ២.៥.១. បង្កើតគណៈកម្មការសម្របសម្រួលផ្នែកសាធារណៈ និងផ្នែកឯកជនរួមបញ្ចូលគ្នានៅថ្នាក់ជាតិ និងថ្នាក់ខេត្ត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង |
| ២.៥.២. បង្កើតយុទ្ធសាស្រ្តលំអិតផ្នែកសេវាសាធារណៈ និងផ្នែកឯកជនរួមបញ្ចូលគ្នា | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ២.៥.៣. អនុវត្តការបណ្តុះបណ្តាលគ្រូបង្គោល | |
| ២.៥.៤. ធ្វើជំរឿនកន្លែងលក់ឱសថឯកជននៅក្នុងស្រុកប្រតិបត្តិសាកល្បង | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ (រួមជាមួយបុគ្គលិកសុខាភិបាលនៅស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព) |
| ២.៥.៥. ធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងចុះហត្ថលេខាលើអនុសារណៈយោគយល់គ្នា | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ២.៥.៦. បណ្តុះបណ្តាលអ្នកផ្តល់សេវាឯកជនអំពីរបៀបផ្តល់របាយការណ៍ករណី | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ២.៥.៧. អនុវត្តការអភិបាល និងតាមដានជាប្រចាំទៅដល់គ្លីនិកឯកជន និងកន្លែងលក់ឱសថ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ (រួមជាមួយបុគ្គលិកនៅថ្នាក់ស្រុក ប្រតិបត្តិ និង ថ្នាក់មណ្ឌលសុខភាព) |
| ២.៥.៨. ណែនាំពីការលើកសរសើរ និងការផ្តល់សច្ចាប័នដើម្បីពង្រឹងការផ្តល់សេវាព្យាបាលដោយសេវាសាធារណៈ និងឯកជន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ២.៥.៩. ប្រារពពិធីផ្តល់រង្វាន់ និងសិក្ខាសាលារៀងរាល់៦ខែម្តង | |
| ២.៥.១០. រៀបចំការស្រាវជ្រាវដោយផ្អែកទៅលើវិស័យ | |

| | |
|---|---|
| ឯកជន ដូចជាការស្រាវជ្រាវសង្គម ទៅលើទំលាប់ និងការអនុវត្តនៃការធ្វើតេស្តរោគវិនិច្ឆ័យ | |
| **ទិសដៅជាយុទ្ធសាស្ត្រទី៣**: ធានាបាននូវការទទួលយកសេវាបង្ការជាពិសេសការបង្ការការចម្លងមេរោគគ្រុនចាញ់ដែលមានភាពស៊ាំនឹងថ្នាំអាតេមីស៊ីនីន ក្នុងចំណោមប្រជាជនគោលដៅ តាមរយៈការត្រួតពិនិត្យសត្វមូសដែលជាភ្នាក់ងារចម្លងជំងឺ និងមធ្យោបាយការពារដោយខ្លួនឯងផ្ទាល់ និងការកែលំអបរិស្ថាន។ | |
| **៣.១. សម្រេចបានការគ្របដណ្តប់ជាសកលនូវមុងជ្រលក់ថ្នាំទៅដល់ក្រុមប្រជាជនប្រឈម** | |
| ៣.១.១. រៀបចំការចាត់ថ្នាក់ និងផែនទីនៃបណ្តាភូមិងាយរងគ្រោះ និងក្រុមគោលដៅសម្រាប់កម្មវិធីមុងជ្រលក់ថ្នាំ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៣.១.២. មុង និងមុងអង្រឹងជ្រលក់ថ្នាំ (LLINs និង LLHINs) ត្រូវបានធ្វើលទ្ធកម្ម | |
| ៣.១.៣. បង្កើតនិងបោះពុម្ពមគ្គុទ្ទេសក៍ស្តីពីការចែកចាយមុង | |
| ៣.១.៤. បណ្តុះបណ្តាល និងបណ្តុះបណ្តាលឡើងវិញដល់ PHD, OD, HC, VHV, VMW អាជ្ញាធរមូលដ្ឋាន និងអ្នកដឹកនាំស្ត្រីស្តីពីការ ប្រើប្រាស់ LLINs និងសម្ភារៈអប់រំសុខភាពឲ្យបានត្រឹមត្រូវ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ៣.១.៥. ចែកចាយ LLINs ដល់ប្រជាជនគោលដៅតាមរយៈការ ធ្វើយុទ្ធនាការរួមបញ្ចូលជាមួយនិងមូលដ្ឋានសុខាភិបាលព្រមទាំងធានាដល់ការគ្របដណ្តប់ដោយ LLINs ក្នុងតំបន់ចម្លងជំងឺ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ មានការគាំទ្រពីឃ្លាំងឱសថកណ្តាល និង ដៃគូ |
| ៣.១.៦. ផ្តល់ជូនដោយឥតគិតថ្លៃនូវ LLINs និងLLIHNs ដល់ប្រជាជន ចល័តនិងចំណាកស្រុករួមទាំងកម្មករឆ្លងដែនតាមរដូវកាល និងអ្នក តាំងទីលំនៅថ្មីដែលមកពីក្រៅតំបន់គោលដៅរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ដែលមានចំងាយ២គីឡូម៉ែត្រពីព្រៃភ្នំ | |
| ៣.១.៧. ផ្តល់ឲ្យនូវការការពារជាបុគ្គលប្រឆាំងមេរោគគ្រុនចាញ់ ដល់យោធា នគរបាល ស្ថាប័នផ្សេងៗទៀត ដែលកំពុងធ្វើការនៅតំបន់ព្រៃភ្នំ តាមជាយដែនកម្ពុជា ថៃ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ សហការជាមួយក្រសួងការពារជាតិ |
| **៣.២ សម្រេចបានការគ្របដណ្តប់ជាសកលនូវមុងអង្រឹងជ្រលក់ថ្នាំ ទៅដល់ក្រុមប្រជាជនប្រឈម** | |
| ៣.២.១. ចែកមុងជ្រលក់ថ្នាំ មុងអង្រឹង និងថ្នាំសម្លាប់មូសដោយឥតគិតថ្លៃ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ មានការគាំទ្រពីឃ្លាំងឱសថកណ្តាល និង ដៃគូ |
| **៣.៣. បង្កើនការគ្របដណ្តប់នូវការជ្រលក់មុងសារឡើងវិញ** | |

| | |
|---|---|
| ៣.៣.១. អនុវត្តន៍ការជ្រលក់មុងធម្មតាដែលមានស្រាប់ឡើងវិញនៅតាមភូមិ តាមរយៈវិស័យសាធារណៈ (នៅទូទាំងប្រទេស)។ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៣.៣.២. ធានាថាមុងដែលបានផ្សព្វផ្សាយលក់ និងមុងអង្រឹងត្រូវបានជ្រលក់ថ្នាំ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| **៣.៤. អនុវត្តការបាញ់ថ្នាំមូសក្នុងផ្ទះ** | |
| ៣.៤.១. បង្កើតនូវនីតិវិធីដំណើរការតាមកម្រិតបទដ្ឋាន | |
| ៣.៤.២. កំណត់ទីតាំងភូមិសាស្រ្ត រៀបចំផែនការ និងប៉ាន់ប្រមាណនូវតម្រូវការ | |
| ៣.៤.៣. ធ្វើលទ្ធកម្មនូវថ្នាំសម្លាប់មូសនិងសម្ភារៈផ្សេងៗ | |
| ៣.៤.៤. បណ្តុះបណ្តាលធនធានមនុស្សបើចាំបាច់ | |
| ៣.៤.៥. ធានាគុណភាពសម្រាប់ថ្នាំសម្លាប់មូស និងសម្ភារៈ | |
| ៣.៤.៦. អនុវត្តការបាញ់ថ្នាំមូសក្នុងផ្ទះឲ្យបានសមស្រប | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៣.៤.៧. តាមដាននូវគុណភាពនិងការគ្របដណ្តប់ការបាញ់ថ្នាំមូសក្នុងផ្ទះ | |
| ៣.៤.៨ ពង្រីកការបាញ់ថ្នាំមូសក្នុងផ្ទះទៅដល់តំបន់ឆ្ងាយពីតំបន់១ និង២ (បើអាចធ្វើបាន) និងបង្កើតនូវកម្មវិធីដើម្បីវាយតម្លៃពីប្រសិទ្ធភាព | |
| **៣.៥. ពង្រឹងនូវការគ្រប់គ្រង និង ការប្រើប្រាស់ត្រឹមត្រូវនូវថ្នាំសម្លាប់មូសក្នុងសុខភាពសាធារណៈ** | |
| ៣.៥.១. បង្កើត និងពិនិត្យជាប្រចាំនូវការធានាគុណភាពសម្រាប់ផលិតផលកំចាត់ភ្នាក់ងារចម្លង ដោយប្រើប្រាស់កម្រិតបទដ្ឋានរបស់អង្គការសុខភាពពិភពលោក | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| **៣.៦. អនុវត្តនូវការសិក្សាស្រាវជ្រាវប្រតិបត្តិសមស្រប** | |
| ៣.៦.១. ធ្វើការស្រាវជ្រាវពីភាពទទួលយកនូវមុងគ្រប់ប្រភេទ និងការសិក្សាផ្នែកបាណកសាស្រ្តនៅតាមតំបន់ដែលមានបម្រែបម្រួលអេកូឡូហ្ស៊ីនៃព្រៃឈើ ជាពិសេសទាក់ទងនឹងការប្រើប្រាស់ថ្នាំសត្វឃាតសម្រាប់ IRS និងវាយតម្លៃចំពោះការ ការពារបន្ថែមពីការប្រើប្រាស់ថ្នាំសម្លាប់សត្វ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| **៣.៧. ផ្តល់ការអប់រំចំពោះអ្នកប្រើប្រាស់និងប្រជាជនទូទៅពីវិធាន ការណ៍ការពារតាមរយៈវិធីសាស្រ្តផ្លាស់ប្តូរឥរិយាបថ និងការទំនាក់ទំនងដ៏មានប្រសិទ្ធភាព** | |

<table>
<tr><td>៣.៧.១. បង្កើតសម្ភារៈអប់រំសុខភាពបន្ថែម ពីការការពារត្រឹមត្រូវ ដោយផ្តោតលើការប្រើប្រាស់មុងជ្រលក់ថ្នាំ</td><td rowspan="2">មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព និងដៃគូ</td></tr>
<tr><td>៣.៧.២. រៀបចំការលើកកំពស់សុខភាពទ្រង់ទ្រាយធំ និងចលនាប្រជាជនក្នុងសហគមន៍ ដើម្បីធានាបានលទ្ធផលខ្ពស់ក្នុងយុទ្ធនាការប្រើមុងជ្រលក់ថ្នាំ និងជំរុញការប្រើប្រាស់មុងមានប្រសិទ្ធភាព</td></tr>
<tr><td colspan="2"><u>ទិសដៅជាយុទ្ធសាស្ត្រទី៤</u>: ធានាបានការយល់ដឹងទូលំទូលាយរបស់សហគមន៍អំពីជំងឺគ្រុនចាញ់ និងការប្រកាន់យកឥរិយាបថត្រឹមត្រូវក្នុងការបង្ការការចម្លងជំងឺគ្រុនចាញ់ ចលនាសហគមន៍ និងការគាំទ្រកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់។</td></tr>
<tr><td>៤.១. បង្កើនចំណេះដឹងប្រជាជន និងអនុវត្តការងារទាក់ទងនឹងការ ការពារនិងលុបបំបាត់ជំងឺគ្រុនចាញ់តាមរយៈវិធីសាស្ត្រផ្លាស់ប្តូរឥរិយាបថមានប្រសិទ្ធភាព ជាពិសេសនៅតាមតំបន់ប្រឈម</td><td></td></tr>
<tr><td>៤.១.១. ពង្រីកនូវសកម្មភាពផ្លាស់ប្តូរឥរិយាបថ ឲ្យឈានដល់ប្រជាជនងាយទទួលរងគ្រោះ។</td><td rowspan="2">មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព</td></tr>
<tr><td>៤.១.២. អនុវត្តវគ្គបណ្តុះបណ្តាលពីកញ្ចប់អប់រំផ្លាស់ប្តូរឥរិយាបថនៅគ្រប់កម្រិត</td></tr>
<tr><td>៤.១.៣. អនុវត្តវិធីសាស្ត្រផ្លាស់ប្តូរឥរិយាបថ សម្ភារៈអប់រំសុខភាព រួមទាំងយុទ្ធនាការទំនាក់ទំនងអន្តរបុគ្គល ចលនាប្រជាជនក្នុងសហគមន៍ និងកិច្ចទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយឲ្យបានទៀងទាត់ជាមួយសារដែលផ្តល់ និងជំនួយពីផ្នែកដែលពាក់ព័ន្ធ ដូចជា វិស័យអប់រំសុខមាលភាពស្ត្រី ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ជាដើម។ល។</td><td rowspan="4">មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព និងដៃគូ</td></tr>
<tr><td>៤.១.៤. ផ្តល់នូវវិធានការណ៍ការពារក្នុងសហគមន៍តាមរយៈអ្នកស្ម័គ្រចិត្តភូមិដូចជា VHVs/ VHSGs/ VMWs/ MMWs</td></tr>
<tr><td>៤.១.៥.បន្តសកម្មភាពផ្លាស់ប្តូរឥរិយាបថ រួមទាំងការអប់រំសុខភាពតាមសាលា (ការបញ្ចាំងវីដេអូ សំណួរ-ចម្លើយ សំដែងល្ខោន ចាប់ឆ្នោតសំណាង និងល្បែងកំសាន្តផ្សេងៗ) ។</td></tr>
<tr><td>៤.១.៦. បន្តការតាមដានការអនុវត្តផ្នែកកិច្ចទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថ និងធ្វើការស្រាវជ្រាវ ដើម្បីវាយតម្លៃលើផលប៉ះពាល់ និងលទ្ធផលពីការផ្លាស់ប្តូរឥរិយាបថនេះ</td></tr>
</table>

| | |
|---|---|
| ៤.១.៧. ជំរាបប្រាប់ប្រជាជនចល័តចេញចូល ពីគ្រោះថ្នាក់នៃជំងឺគ្រុនចាញ់ ការការពារ និងរោគវិនិច្ឆ័យ តាមរយៈមិត្តអប់រំមិត្ត និងយុទ្ធនាការផ្លាស់ប្តូរឥរិយាបថនៅសហគមន៍ និងតាមរយៈនិយោជក និងភ្នាក់ងារនៅតំបន់ធ្វើការ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់<br>មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព<br>និងដៃគូ |
| ៤.១.៨. រួមសហការបញ្ចូលគ្នានូវការផ្លាស់ប្តូរឥរិយាបថទៅដល់ក្រុមប្រជាជនចល័តតាមព្រំដែន ក្នុងកិច្ចសហប្រតិបត្តិការជាមួយភាគីថៃ និងដៃគូនានា។ | |
| ៤.១.៩. បង្កើតនិងវាយតម្លៃពីប្រសិទ្ធភាពនៃកិច្ចអន្តរាគមន៍ជាមួយចលនាប្រជាជនចល័ត និងឥរិយាបថ ក្នុងកិច្ចសហការណ៍ជាមួយ ដៃគូដែលពាក់ព័ន្ធ។ | |
| ៤.១.១០. រៀបចំការស្រាវជ្រាវសង្គមៈ ក្រិតក្រមវប្បធម៌ចំពោះ វិធីសាស្ត្រទប់ស្កាត់ និង ព្យាបាលប្រឆាំងនឹងជំងឺគ្រុនចាញ់ ក្នុងចំណោមប្រជាជន។ | |
| **៤.២. ពង្រឹងនូវកិច្ចខិតខំផ្នែកផ្លាស់ប្តូរឥរិយាបថ ចំពោះការធ្វើរោគវិនិច្ឆ័យ និងព្យាបាលគ្រុនចាញ់ទាន់ពេលវេលា** | |
| ៤.២.១. រចនា បង្កើត និងចែកចាយសម្ភារៈអប់រំសុខភាព | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់<br>មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព<br>និងដៃគូ |
| **៤.៣. លើកកំពស់ការប្រើប្រាស់ដ៏សមស្របនូវថ្នាំគ្រុនចាញ់ទៅដល់ប្រជាជនប្រឈម តាមរយៈកិច្ចខិតខំផ្នែកផ្លាស់ប្តូរឥរិយាបថដ៏ពេញលេញ** | |
| ៤.៣.១. បង្កើត និង ប្រើប្រាស់សម្ភារៈអប់រំសុខភាពដល់សាធារណៈពីការប្រើប្រាស់ឱសថសមស្របសម្រាប់ព្យាបាលជំងឺគ្រុនចាញ់។ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់<br>មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព<br>និងដៃគូ |
| **៤.៤. ផ្លាស់ប្តូរឥរិយាបថចាស់ដែលនាំដល់ការរីករាលដាលមេរោគគ្រុនចាញ់ និងជំរុញលើកទឹកចិត្ត ការធ្វើតេស្តវិភាគ និងព្យាបាលឲ្យសមស្រប ដោយប្រើប្រាស់បន្ទះថ្នាំ ACT បញ្ចូលគ្នា។** | |
| ៤.៤.១. ត្រូវមានការចូលរួមពីក្រុមការងារផ្នែកផ្លាស់ប្តូរឥរិយាបថ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់<br>មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព<br>និងដៃគូ |
| ៤.៤.២. ផលិតនិង ចែកចាយនូវសារឲ្យចំគោលដៅ | |
| ៤.៤.៣. អនុវត្តតាមរយៈគម្រោង AMFm នៅក្នុងខេត្តចំនួន ២០ ដែលប្រឈមនឹងជំងឺគ្រុនចាញ់ | |
| ៤.៤.៤. លើកទឹកចិត្តការប្រើប្រាស់រូបឡូហ្គូមានគុណភាពខ្ពស់លើបន្ទះថ្នាំគ្រុនចាញ់ ACT | |
| ៤.៤.៥. ធ្វើយុទ្ធនាការតាមទូរទស្សន៍ | |

| | |
|---|---|
| ៤.៤.៦. ផលិតកម្មវិធីវិទ្យុ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់<br>មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព<br>និងដៃគូ |
| ៤.៤.៧. បង្កើតនូវសម្ភារៈពាក់កណ្ដាលព័ត៌មាន | |
| ៤.៤.៨. រចនា និងដាក់រូបផ្សព្វផ្សាយធំៗជាមួយសារអប់រំសំខាន់ៗ | |
| ៤.៤.៩. រចនា និងផលិតរូបភាពសន្លឹកបត់ ឲ្យបាន ១ម៉ឺន ស្ដីពី ការប្រើប្រាស់ថ្នាំឲ្យបានត្រឹមត្រូវ | |
| ៤.៤.១០. ផលិតសម្ភារៈផ្នែកផ្សព្វផ្សាយ និងជំនួយដល់ការងារ | |
| <u>**ទិសដៅជាយុទ្ធសាស្ត្រទី៥**</u>: ធ្វើការគ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាពរួមបញ្ចូលទាំងប្រពន្ធ័ព័ត៌មានសុខាភិបាល និងការតាមដាន ព្រមទាំងការសម្របសម្រួលនានាដែលនឹងនាំឲ្យការអនុវត្តយុទ្ធសាស្ត្រនៃការលុបបំបាត់ជំងឺគ្រុនចាញ់មានគុណភាពខ្ពស់ និងទទួលបានជោគជ័យ។ | |
| **៥.១. ពង្រឹងនូវការគ្រប់គ្រងធនធានមនុស្ស តាមរយៈដំណោះស្រាយលើកង្វះបុគ្គលិក និងការកសាងសមត្ថភាពគ្រប់កម្រិត ទាំងនៅថ្នាក់កណ្ដាល និងថ្នាក់អនុវត្តនៅមូលដ្ឋាន** | |
| ៥.១.១. កំណត់រកការខ្វះខាតធនធានមនុស្ស និងដោះស្រាយ | ក្រសួងសុខាភិបាល |
| ៥.១.២. ពង្រឹងនូវធនធានមនុស្ស | |
| ៥.១.៣. កសាងសមត្ថភាពធនធានមនុស្ស | |
| **៥.២. ពង្រឹងនូវសកម្មភាព តាមដាននិងវាយតម្លៃ នៅថ្នាក់កណ្ដាល និងថ្នាក់អនុវត្តនៅមូលដ្ឋាន** | |
| ៥.២.១. ពង្រឹង និងរក្សានូវសកម្មភាពតាមដាននិងវាយតម្លៃ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៥.២.២. ធ្វើការអភិបាលគាំទ្រឲ្យបានខ្លាំងក្លា | |
| ៥.២.៣. ពិនិត្យនូវការកម្មវិធីគ្រុនចាញ់ឲ្យបានទៀងទាត់ | |
| **៥.៣. ពង្រឹងនូវការគ្រប់គ្រងព័ត៌មាននៅគ្រប់កម្រិត** | |
| ៥.៣.១. ផ្ដល់នូវការបណ្ដុះបណ្ដាលផ្នែកអេពីដេមីសាស្ត្រនៅគ្រប់កម្រិត រួមទាំងការគ្រប់គ្រងទិន្នន័យ ការវិភាគ និងគូសផែនទី | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់<br>និងដៃគូ |
| ៥.៣.២. បង្កើត និងរក្សានូវទិន្នន័យជំងឺគ្រុនចាញ់នៅថ្នាក់ជាតិ (រួមទាំងទិន្នន័យ HIS ទិន្នន័យមុងជ្រលក់ថ្នាំ ការតាមដានថ្នាំ ការ អង្កេត និងការបណ្ដុះបណ្ដាលបុគ្គលិកជាដើម។ល។ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៥.៣.៣. បណ្ដុះបណ្ដាលបុគ្គលិកនៅថ្នាក់ស្រុកប្រតិបត្តិស្ដីពីការគ្រប់គ្រងទិន្នន័យ និងការរាយការណ៍ | |

| | |
|---|---|
| ៥.៣.៤. បញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រសម្រាប់ការរាយការណ៍ នៅថ្នាក់ខេត្ត និងស្រុកប្រតិបត្តិ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៥.៣.៥. គាំទ្រការវិភាគទិន្នន័យ បកស្រាយ និងការសរសេររបាយការណ៍នៅថ្នាក់មូលដ្ឋាន | |
| ៥.៣.៦.រក្សា និងពង្រីកនូវប្រព័ន្ធតាមដានជំងឺគ្រុនចាញ់ទូលំទូលាយ ព្រមទាំងប្រព័ន្ធតាមដាន អង្កេតករណីសកម្ម និងតាមដានអង្កេតករណីនៅតាមព្រំប្រទល់ផងដែរ | |
| ៥.៣.៧. ពង្រឹងនូវប្រព័ន្ធតាមដាន ដើម្បីទទួលបាន និងផ្លាស់ប្តូរព័ត៌មានសំខាន់ៗទាក់ទងនឹងជំងឺគ្រុនចាញ់ និងប្រជាជនចល័ត | |
| ៥.៣.៨. ធ្វើឲ្យប្រសើរឡើងនូវការប្រមូលទិន្នន័យ ស្តីពីការធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺក្នុងវិស័យឯកជន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| **៥.៤. ពង្រឹងនូវការស្រាវជ្រាវប្រតិបត្តិ និងអនុវត្តការស្រាវជ្រាវប្រតិបត្តិតាមតម្រូវការ** | |
| ៥.៤.១. អនុវត្តការស្រាវជ្រាវ និងតាមដានាភាពស៊ាំនឹងថ្នាំសម្លាប់សត្វល្អិត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៥.៤.២. បង្កើត និងពង្រឹងនូវជំនាញបាណសាស្ត្រនៅថ្នាក់ជាតិ និងខេត្ត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៥.៤.៣. ផ្សព្វផ្សាយនូវលទ្ធផលស្រាវជ្រាវប្រតិបត្តិ និងបង្កើតនូវ ផែនការយុទ្ធសាស្ត្រអនុវត្តចំពោះប្រជាជនចល័តឲ្យមានប្រសិទ្ធភាព | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ៥.៤.៤. រៀបចំការសិក្សាដើម្បីវាយតម្លៃពីការប្រតិបត្តិតាម EDAT និងឥរិយាបថការការពារជំងឺនៃប្រជាជនគោលដៅ | |
| ៥.៤.៥. ធ្វើការសិក្សាដើម្បីប្រៀបធៀប Sensitivity, Specificity និង ជាពិសេសតម្លៃនៃ RDTs. | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៥.៤.៦. ពង្រឹងសមត្ថភាពស្រាវជ្រាវ (រួមទាំងការបណ្តុះបណ្តាល និងសម្ភារៈផ្នែកតាមតម្រូវការ) | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងការគាំទ្រពីអង្គការសុខភាពពិភពលោក |
| **៥.៥. ពង្រឹងនូវកិច្ចសម្របសម្រួល សហការ និងភាពជាដៃគូអភិវឌ្ឍន៍ នៅកម្រិតមណ្ឌលសុខភាព និងកម្រិតសហគមន៍** | |
| ៥.៥.១. ផ្តល់ការគាំទ្រ ការខិតខំចូលរួមធ្វើផែនការសម្រាប់សកម្មភាពលុបបំបាត់ជំងឺគ្រុនចាញ់នៅថ្នាក់ឃុំ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |

| | |
|---|---|
| ៥.៥.២. ទាញការចូលរួមពីដៃគូអភិវឌ្ឍន៍ នៅសហគមន៍ ដើម្បីអនុវត្តសកម្មភាពលុបបំបាត់ជំងឺគ្រុនចាញ់ រួមទាំង នៅមន្ទីរពេទ្យបង្អែក | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| **៥.៦. ពង្រឹងនូវកិច្ចសម្របសម្រួល សហការ និងការអភិវឌ្ឍ ភាពជាដៃគូនៅកម្រិតស្រុកប្រតិបត្តិ** | |
| ៥.៦.១. គាំទ្រការរៀបចំ សិក្ខាសាលាជាទៀងទាត់ពីជំងឺ គ្រុនចាញ់នៅថ្នាក់ខេត្ត និងស្រុកប្រតិបត្តិ រួមទាំង ទស្សនកិច្ចសិក្សារវាងខេត្ត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងដៃគូ |
| ៥.៦.២. រៀបចំកិច្ចប្រជុំសម្របសម្រួលនៅថ្នាក់ខេត្ត ជាពិសេស ពិភាក្សា អំពីការកំណត់ទីតាំងភូមិសាស្ត្រដែល ប្រឈមនឹងគ្រុនចាញ់ (ជាភូមិ ឃុំ ស្រុក) | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| **៥.៧. ពង្រឹងនូវកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ ភាពជាដៃគូនៅថ្នាក់កណ្តាល** | |
| ៥.៧.១. បង្កើតនូវគណៈកម្មការជាតិ ដឹកនាំការងារ គ្រុនចាញ់ រៀបចំការប្រជុំប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យ និងដោះស្រាយបញ្ហាបច្ចេកទេស និងការប្រឈមផ្សេងៗ | |
| ៥.៧.២. ធានានូវកិច្ចសហប្រតិបត្តិការបច្ចេកទេស លើកិច្ចដំណើរការគម្រោងទប់ស្កាត់ជំងឺគ្រុនចាញ់ រួមទាំងកិច្ចប្រជុំ ទៀងទាត់ពី ក្រុមការងារទប់ស្កាត់ភាពស៊ាំនឹងថ្នាំ អាតេមីស៊ីនីន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៥.៧.៣. អនុវត្តនូវការបំផុសស្មារតី និងតស៊ូមតិ ដើម្បី ទទួលបាន ការគាំទ្រផ្នែកនយោបាយក្នុងការលុបបំបាត់ មេរោគដែលស៊ាំនឹងថ្នាំអាតេមីស៊ីនីន រួមទាំងកិច្ចប្រជុំ តស៊ូមតិជាប្រចាំជាមួយអ្នកដឹកនាំក្នុងសហគមន៍ ថ្នាក់ឃុំ ស្រុក ខេត្ត ជាតិ និងអន្តរជាតិ | |
| ៥.៧.៤. គាំទ្រការផ្សព្វផ្សាយលទ្ធផលការស្រាវជ្រាវ និងផ្លាស់ប្តូរព័ត៌មាន រួមទាំងតាមរយៈកិច្ចប្រជុំប្រចាំឆ្នាំ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| ៥.៧.៥. រៀបចំមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ដើម្បីឲ្យដំណើរការជាមជ្ឈមណ្ឌលសិក្សាមួយក្នុងតំបន់ | |

# ៧- សកម្មភាពការងារ

## ក- សមាសភាគនៃយុទ្ធសាស្ត្រយូរអង្វែង របស់កម្មវធីជាតប្រយុទ្ធនឹងជំងឺគ្រុនចាញ់

យុទ្ធសាស្ត្រគ្រប់គ្រងជំងឺគ្រុនចាញ់រយៈពេលវែង គឺការពង្រីកនូវបទអន្តរាគមន៍នានា ដើម្បីសម្រេចបាននូវការគ្របដណ្តប់ជាសកល ដោយបញ្ឈប់នូវភាពស៊ាំរបស់មេរោគគ្រុនចាញ់ទៅនឹងថ្នាំអាតេមីស៊ីនីន និងឈានទៅរកការត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់ក្នុងអំឡុងឆ្នាំ២០១១ ដល់ ២០១៥ ធានាមិនឲ្យមានការស្លាប់ដោយជំងឺគ្រុនចាញ់ចាប់ពីឆ្នាំ២០២០ ព្រមទាំងឈានទៅរកការលុបបំបាត់ចោលទាំងស្រុងជំងឺគ្រុនចាញ់ ដែលបង្កឡើងដោយមេរោគគ្រប់ប្រភេទក្នុងអំឡុងពីឆ្នាំ២០២១ ដល់ ២០២៥ (ដូចមានក្នុងរូបភាពទី៣)។

ផ្អែកតាមលក្ខណៈអេពីដេមីសាស្ត្រនៃស្ថានភាពជំងឺគ្រុនចាញ់ក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះមានការរំពឹងទុកថា ការលុបបំបាត់ទាំងស្រុងជំងឺគ្រុនចាញ់ជាសកលអាចធ្វើទៅបានក្រោយឆ្នាំ២០៣០ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា យើងសង្ឃឹមថាអាចចូលរួមដោយពេញលេញក្នុងកិច្ចខិតខំប្រឹងប្រែងជាមួយសកលលោកលុបបំបាត់ជំងឺ នេះនៅមុនឆ្នាំ២០៣០ ហើយកម្ពុជានឹងត្រូវត្រួតពិនិត្យការហូរចូលនៃករណីគ្រុនចាញ់ពីខាងក្រៅមកក្នុងប្រទេស ជាពិសេសតាមរយៈការងារសម្របសម្រួលកិច្ចការព្រំដែន។ ឱសថថ្មីៗ សម្ភារៈធ្វើរោគវិនិច្ឆ័យរ៉ាក់សាំង និងឧបករណ៍ផ្សេងៗទៀត ជាមួយនឹងស្ថេរភាពនយោបាយដ៏រឹងមាំនឹងជំរុញឲ្យការលុបបំបាត់ទាំងស្រុងជំងឺគ្រុនចាញ់នៅព្រះរាជាណាចក្រកម្ពុជាអាចសម្រេចបានជាស្ថាពរ។

រូបភាព ទី ៣: យុទ្ធសាស្ត្ររយៈពេលវែង របស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់



## ខ- យុទ្ធសាស្ត្រស្របជាមួយការប្តេជ្ញាចិត្តថ្នាក់ជាតិ និងថ្នាក់សកល

ដោយមើលឃើញថាការកាត់បន្ថយការឈឺ និងការស្លាប់ដោយសារជំងឺគ្រុនចាញ់ជាកត្តាសំខាន់ក្នុងការជំរុញការលូតលាស់ និងអភិវឌ្ឍន៍សង្គមនៅប្រទេសកម្ពុជា គោលបំណងជាយុទ្ធសាស្ត្ររបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ត្រូវបានរៀបចំឡើងដោយតំរង់ស្របទៅតាមក្របខណ្ឌនៃការអភិវឌ្ឍថ្នាក់ជាតិដ៏ទូលំទូលាយ ដូចជាយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីការរីកចំរើន ភាពមានការងារធ្វើ សមធម៌ និងប្រសិទ្ធិពល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ និងផែនការអភិវឌ្ឍសហស្សវត្សរ៍ ព្រមទាំងផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០០៨-២០១៥។

ការខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធ និងការលុបបំបាត់ចោលជំងឺគ្រុនចាញ់ ដែលត្រូវបានដឹកនាំតាមយុទ្ធសាស្ត្រនេះនឹងបន្តដើរតួយ៉ាងសំខាន់ក្នុងការជួយឲ្យប្រទេសជាតិយើង ឈានដល់គោលដៅនៃការប្តេជ្ញាចិត្តជាសកល ដូចជា ក្នុងផែនការអភិវឌ្ឍសហស្សវត្សរ៍ ពិសេសគោលដៅទី៦ ផែនការយុទ្ធសាស្ត្រទប់ស្កាត់ជំងឺគ្រុនចាញ់ឆ្នាំ២០០៥-២០១៥ ផែនការសកម្មភាពប្រយុទ្ធនឹងជំងឺគ្រុនចាញ់ជាសកល ខែសីហា ឆ្នាំ២០០៨ សេចក្តីសម្រេចនៃសន្និបាតសុខភាពពិភពលោកឆ្នាំ១៩៧៧ អំពីសុខភាពបឋមជាដើម ។ ល។

## គ- ដំណាក់កាលនៃការលុបបំបាត់ជំងឺគ្រុនចាញ់

ដោយការឆ្លងនៃជំងឺគ្រុនចាញ់នៅប្រទេសកម្ពុជាយើង បង្កឡើងដោយមេរោគសំខាន់ទាំងពីរប្រភេទ (ហ្វាល់ស៊ីប៉ារ៉ូម និងវីវ៉ាក់) កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់មានគោលបំណងជាដំបូង គឺលុបបំបាត់ប្រភេទមេរោគហ្វាល់ស៊ីប៉ារ៉ូម ព្រោះថា:

- វាបង្កឲ្យមានភាពធ្ងន់ធ្ងរ ធ្វើឲ្យងាយទទួលគ្រោះថ្នាក់
- ដោយសារមានការរកឃើញក្នុងពេលថ្មីៗនូវភាពស៊ាំនឹងថ្នាំអាតេមីស៊ីនីន នៅតាមតំបន់មួយចំនួននៃប្រទេស យើងរំពឹងថាមេរោគហ្វាល់ស៊ីប៉ារ៉ូមដែលនៅសល់ចុងក្រោយ គឺជាមេរោគដែលមានភាពស៊ាំខ្លាំង និងលំបាកក្នុងការបំបាត់ចោល
- សកម្មភាពប្រឆាំងជាមួយហ្វាល់ស៊ីប៉ារ៉ូម ក៏អាចកំចាត់វីវ៉ាក់បានដែរ។

ទោះជាយ៉ាងណា ការលុបបំបាត់ជំងឺគ្រុនចាញ់បង្កដោយវីវ៉ាក់ក៏នឹងត្រូវបានធ្វើផែនការផងដែរ ដើម្បីឲ្យគោលដៅសម្រេចបានក្នុងរយៈពេល៥ឆ្នាំ បន្ទាប់ពីការលុបបំបាត់ហ្វាល់ស៊ីប៉ារ៉ូម។ រូបភាពទី៤ បង្ហាញពីអត្រាអាំងស៊ីដង់បច្ចុប្បន្ននៃករណីជំងឺគ្រុនចាញ់ក្នុងប្រទេសកម្ពុជា។ រូបភាពទី៥ គូសបញ្ជាក់ពីដំណាក់កាលស្នើសម្រាប់ការលុបបំបាត់ជំងឺគ្រុនចាញ់ផ្អែកតាមស្រុកប្រតិបត្តិ។ រូបភាពទី៦ និងទី៧ បង្ហាញអំពីដំណាក់កាលស្នើសម្រាប់ការលុបបំបាត់ជំងឺគ្រុនចាញ់ប្រភេទហ្វាល់ស៊ីប៉ារ៉ូម និងប្រភេទវីវ៉ាក់ ផ្អែកតាមស្រុកប្រតិបត្តិដែរ។

## ឃ- ការគ្រប់ដណ្តប់តំបន់ដែលមានកត្តាអំណោយផលដល់ការលុបបំបាត់ជំងឺគ្រុនចាញ់

តំបន់ដែលមានកត្តាអំណោយផលដូចខាងក្រោម នឹងត្រូវបានដាក់បញ្ចូលទៅក្នុងដំណាក់កាលដំបូងនៃផែនការលុបបំបាត់ ៖

- អត្រានៃការករកើតឡើងវិញរបស់ជំងឺគ្រុនចាញ់មានកម្រិតទាប មធ្យម
- បម្រែបម្រួលនៃការចម្លងជំងឺកើតមានទៅតាមរដូវកាល
- តំបន់ភាគច្រើនដែលមិនសូវមានការរាតត្បាត

- វត្តមានច្បាស់លាស់នៃព្រំដែនធម្មជាតិដែលពាក់ព័ន្ធនឹងការចម្លងគ្រុនចាញ់
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលមូលដ្ឋាន ជាមួយនឹងការរីកចំរើនក្នុងពេលអនាគត
- ភាពសម្បូរណ៍សប្បាយ និងការមានចំណេះដឹងខ្ពស់របស់ប្រជាជន។

គោលដៅរបស់យើងក្នុងតំណាក់កាលនេះគឺមិនមែនត្រឹមតែទៅលើប្រជាជនដែលស្ថិតក្នុងគម្រោងបង្ការភាពស៊ាំជាមួយថ្នាំអាតេមីស៊ីនីនប៉ុណ្ណោះទេ តែរួមបញ្ចូលទាំងក្រុមដែលបោះទីតាំងនៅដាច់ពីគេ ដូចជាកងកម្លាំងប្រដាប់អាវុធ ព្រមទាំងប្រជាជនដែលរស់នៅជនបទដាច់ស្រយ៉ាល រួមទាំងគោលដៅនៅភូមិភាគឥសាន្តក៏នឹងត្រូវដាក់បញ្ចូល ក្នុងដំណាក់កាលនៃការលុបបំបាត់ជាដំបូងនេះផងដែរ (ខេត្តស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី និងក្រចេះ)។ អន្តរាគមន៍គន្លឹះគឺការប្រតិបត្តិនូវប្រព័ន្ធតាមដាននៅក្នុងតំបន់។ ការខិតខំប្រឹងប្រែងខ្ពស់ក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់តាមតំបន់ដែលមានភាពស៊ាំនឹងថ្នាំអាតេមីស៊ីនីននៅភូមិភាគពាយ័ព្យនៃប្រទេស (បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន និងពោធិសាត់) ត្រូវធ្វើមុនគេក្នុងដំណាក់កាលដំបូង ដែលនឹងនាំមកនូវមេរៀនមានសារៈសំខាន់សម្រាប់ ការអនុវត្តនៅដំណាក់កាលបន្តបន្ទាប់នៅតាមភូមិភាគផ្សេងៗទៀតនៃប្រទេសកម្ពុជា។

## ង- **ការគ្រប់ដណ្តប់តំបន់ដែលមានកត្តាពុំអំណោយផលដល់ការលុបបំបាត់ជំងឺគ្រុនចាញ់**

តំបន់ដែលមានកត្តាពុំសូវអំណោយផលដូចខាងក្រោមនឹងត្រូវបានដាក់បញ្ចូលទៅក្នុងដំណាក់កាលនៃការលុបបំបាត់ជាចុងក្រោយ ៖

- តំបន់ដែលមានភ្នាក់ងារចម្លងខ្លាំង និងការចម្លងតាមរដូវកាលមានរយៈពេលវែង
- ការអភិវឌ្ឍនៅតំបន់ដាច់ស្រយ៉ាលនៅមានកម្រិត ជាពិសេសប្រជាជនរស់នៅមិនប្រមូលផ្តុំ និងមានហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងការគ្របដណ្តប់ខ្វះខាតនៅឡើយ
- តំបន់ព្រំដែនរួមជាមួយប្រទេសជិតខាងដែលបន្ទុកនៃបញ្ហានៅមានកម្រិតខ្ពស់
- ចលនាឆ្លងកាត់ព្រំដែនដ៏មមាញឹករបស់ប្រជាជន និងអត្រាចំណាកស្រុកខ្ពស់ឆ្លងកាត់ប្រទេសដែល មានការរាតត្បាត
- របាំង ឧបស័គ្គដែលពាក់ព័ន្ធកត្តាភូមិសាស្ត្រ និងកត្តាសេដ្ឋកិច្ច។

រូបភាពទី៤: ផែនទីបច្ចុប្បន្នភាពនៃអត្រាឈឺ (អាចស៊ីដង់) ជំងឺគ្រុនចាញ់ក្នុងប្រទេសកម្ពុជា (២០១០)

Malaria incidence of confirmed case by Operational District
in Cambodia 2010




រូបភាពទី៥: ផែនទីបង្ហាញពីដំណាក់កាលលុបបំបាត់ជំងឺគ្រុនចាញ់តាមស្រុកប្រតិបត្តិ (២០១៥-២០២៥)

Malaria Elimination by Operational District
in Cambodia (2015-2025)



រូបភាពទី៦: ផែនទីបង្ហាញពីដំណាក់កាលលុបបំបាត់ជំងឺគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូម (ដល់ឆ្នាំ២០២០)

Pf Malaria Elimination by Operational District in Cambodia (2015-2020)




រូបភាពទី៧: ផែនទីបង្ហាញពីដំណាក់កាលលុបបំបាត់ជំងឺគ្រុនចាញ់វីវ៉ាក់ (ដល់ឆ្នាំ២០២៥)

Pv Malaria Elimination by Operational District in Cambodia (2015-2025)



## ច- អន្តរាគមន៍ក្នុងអំឡុងពេលត្រៀមលុបបំបាត់ ឆ្នាំ២០១១-២០១៥

- ផ្តល់ដល់ប្រជាជនទាំងអស់ទទួលបាននូវសេវាសុខភាពសាធារណៈពេញលេញដែលអាចជឿទុកចិត្តបានដោយឥតគិតថ្លៃ
- បញ្ជាក់ច្បាស់ពីករណីជំងឺដោយបច្ចេកទេសបំពាក់ពណ៌ ដោយពិនិត្យមីក្រូទស្សន៍ដែលមានការធានាគុណភាព ឬការពិនិត្យដោយតេស្តរហ័សចំពោះមេរោគវីវ៉ាក់ ការអនុវត្ត និងពង្រីកការធ្វើតេស្ត G6PD
- ធ្វើការផ្លាស់ប្តូរគោលនយោបាយប្រើប្រាស់ឱសថ ដោយបូកបញ្ចូលបន្ថែមការប្រើប្រាស់ថ្នាំសម្លាប់ហ្គាម៉េតសម្រាប់ព្យាបាលហ្វាល់ស៊ីប៉ារ៉ូម
- មានប្រព័ន្ធព័ត៌មានសុខាភិបាលគ្របដណ្តប់គ្រប់សេវាសុខភាព
- ស្រាវជ្រាវសកម្មករណីជំងឺគ្រុនចាញ់ក្នុងចំណោមក្រុមជនងាយរងគ្រោះ
- អនុវត្តសាកល្បង និងពង្រីកបន្ថែម ការផ្តល់ថ្នាំព្យាបាលជំងឺជាសមូហភាព(MDA) ឬការពិនិត្យដោះឈាម និងផ្តល់ថ្នាំព្យាបាលជំងឺផ្តោតតាមទីកន្លែងដែលបានជ្រើសរើស (FSAT)
- ផ្តល់ព័ត៌មានឲ្យបានឆាប់រហ័សរាល់គ្រប់ករណីជំងឺគ្រុនចាញ់
- មានបុគ្គលិកធ្វើការអង្កេតតាមដាន និងបែងចែកតាមករណីជំងឺនិមួយៗ
- ពង្រឹងការចូលរួមរបស់សហគមន៍ និងស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រងទៅលើផ្នែកឯកជន
- គ្រប់គ្រងឲ្យបានពេញលេញទៅលើកន្លែងផ្គត់ផ្គង់ឱសថព្យាបាលគ្រុនចាញ់ រួមមាន:
  - គ្រប់ឱសថព្យាបាលជំងឺគ្រុនចាញ់ត្រូវបានផ្តល់ជូនឲ្យដោយឥតគិតថ្លៃនៅតាមសេវាសុខភាពសាធារណៈ
  - គ្មានការព្យាបាលជំងឺគ្រុនចាញ់នៅតាមផ្ទះ (លើកលែងតែតាមរយៈអ្នកស្ម័គ្រចិត្តព្យាបាលគ្រុនចាញ់តាមភូមិ) មានតែឱសថគ្រុនចាញ់ដែលបានណែនាំក្នុងមគ្គុទ្ទេសក៏ព្យាបាលថ្នាក់ជាតិ ត្រូវបានអនុញ្ញាតឲ្យលក់នៅតាមហាង និងឱសថស្ថាន
  - រៀបចំឲ្យមានរបៀបរៀបរយសកម្មភាពធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺគ្រុនចាញ់ នៅតាមសេវាឯកជន
- ធ្វើការសិក្សាឲ្យបានច្បាស់លាស់ពីលក្ខណៈភូមិសាស្ត្រ
- មានទិន្នន័យពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ អំពីទីកន្លែង ភ្នាក់ងារចម្លងជំងឺ ករណីជំងឺ ប្រភេទមេរោគ
- មានកំនត់ត្រានៅថ្នាក់កណ្តាល និងការទុកដាក់ក្រុមមេរោគដោយឡែកៗពីគ្នាសម្រាប់ការសិក្សាការសិក្សាអំពីហ្សេនេទិក
- វត្តមានបុគ្គលិកដែលបានបណ្តុះបណ្តាល និងមានសមត្ថភាពនៅតាមមូលដ្ឋានសុខាភិបាល
- មានការលើកទឹកចិត្ត ជាពិសេសចំពោះបុគ្គលិកដែលធ្វើការពាក់ព័ន្ធនឹងយុទ្ធសាស្ត្រត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់ (ដោយពិចារណាផ្តល់ប្រាក់លើកទឹកចិត្តសមស្រប)
- ធ្វើចលនាប្រមូលធនធានហិរញ្ញវត្ថុក្នុងស្រុក
- ផ្តួចផ្តើមគំនិតតាមភូមិភាគ
- សម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាអន្តរវិស័យ។

### ឆ- អន្តរាគមន៍ក្នុងអំឡុងពេលលុបបំបាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០១៦-២០២០

- ការធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺដោយឥតគិតថ្លៃនៅគ្រប់ផ្នែក (ទាំងផ្នែកសាធារណៈ ឯកជន និងនៅតាមសហគមន៍)
- ធ្វើតេស្ត G6PD ជាប្រចាំ ទៀងទាត់
- ធ្វើការស្រាវជ្រាវគ្រប់ករណីជំងឺ ដោយរាប់បញ្ចូលទាំង:
  - ការបញ្ជាក់អះអាងរោគវិនិច្ឆ័យគ្រប់ករណីជំងឺគ្រុនចាញ់ ដោយប្រើមីក្រូទស្សន៍ប្រកបដោយគុណភាព (កាត់បន្ថយការពិនិត្យរកមេរោគដោយប្រើតេស្តរហ័សជាបណ្តើរៗ លើកលែងតែអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ)
  - ប្រព័ន្ធព័ត៌មានគ្រុនចាញ់ដែលរឹងមាំត្រូវបានគ្របដណ្តប់លើគ្រប់មូលដ្ឋានសុខាភិបាលសាធារណៈ: ការកំណត់ករណីជំងឺគ្រុនចាញ់
  - ការស្រាវជ្រាវសកម្មនូវករណីជំងឺគ្រុនចាញ់
- ការពារការចម្លងមេរោគ ដោយរាប់បញ្ចូលទាំងការគ្របដណ្តប់ពេញលេញ ការផ្តល់ជូនដោយឥតគិតថ្លៃនូវឱសថគ្រុនចាញ់ដែលមានប្រសិទ្ធភាពចំពោះអ្នកជំងឺទាំងអស់
- ធ្វើការបណ្តុះបណ្តាលអ្នកជំនាញមីក្រូទស្សន៍ជាទៀតទាត់
- ធ្វើការសិក្សាជាតិពន្ធុ (Genotyping) ជាទៀងទាត់
- អនុវត្តនូវគោលនយោបាយប្រើប្រាស់ឱសថគ្រុនចាញ់ថ្មី
- អនុវត្តសាកល្បង និងពង្រីកបន្ថែម ការផ្តល់ថ្នាំព្យាបាលជំងឺជាសម្ងហភាព(MDA) ឬការពិនិត្យដោះឈាម និងផ្តល់ថ្នាំព្យាបាលជំងឺផ្តោតតាមទីកន្លែងដែលបានជ្រើសរើស(FSAT)
- ធ្វើកិច្ចសហប្រតិបត្តិការពេញលេញជាមួយផ្នែកឯកជន
- ផ្តល់ព័ត៌មានឲ្យបានឆាប់រហ័សរាល់គ្រប់ករណីជំងឺគ្រុនចាញ់
- ធ្វើការអង្កេត និងបែងចែកតាមប្រភេទករណីជំងឺគ្រុនចាញ់
- ផ្តោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងជំងឺគ្រុនចាញ់ (ការអង្កេត និងបែងចែកតាមប្រភេទករណីជំងឺ) ដោយរាប់បញ្ចូលទាំង:
  - ធ្វើការសិក្សាឲ្យស្គាល់ច្បាស់ពីទីតាំងភូមិសាស្ត្រ
  - ធ្វើការបែងចែកតាមប្រភេទករណីជំងឺ និងផ្តោតសំខាន់ទៅលើស្ថានភាពជំងឺបច្ចុប្បន្ន (ក្នុងពេលវេលាជាក់លាក់)
  - អត្រាគ្របដណ្តប់ដោយមុងជ្រលក់ថ្នាំពេញលេញ ដែលជាវិធានការការពារដ៏សំខាន់នៅគ្រប់តំបន់ដែលមានអត្រាចម្លងជំងឺគ្រុនចាញ់ខ្ពស់ (អត្រាគ្របដណ្តប់លើសពី ៩៥ភាគរយ)
  - បង្កើនសេវាសុខភាពទូទៅឲ្យកាន់តែប្រសើរឡើងដោយយកចិត្តទុកដាក់ខ្ពស់លើប្រព័ន្ធតាមដាន
- គ្រប់គ្រងទៅលើលំហូរចូលនូវពពួកប៉ារ៉ាស៊ីតដោយធ្វើសហប្រតិបត្តិការជាមួយនឹងអន្តរប្រទេស
- ការពារជំងឺគ្រុនចាញ់ចំពោះក្រុមអ្នកដំណើរ
- សម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាអន្តរវិស័យ (រួមជាមួយយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រសួងមន្ទីរពាក់ព័ន្ធនានា មានក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។ល។)

- មានការលើកទឹកចិត្ត ជាពិសេសចំពោះបុគ្គលិកដែលធ្វើការពាក់ព័ន្ធនឹងយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់ (ដោយពិចារណាផ្តល់ប្រាក់លើកទឹកចិត្តសមស្រប)។

## ង- គោលដៅគន្លឹះ

តារាងខាងក្រោមបង្ហាញពីគោលដៅដោយប្រៀបជាមួយនឹងសូចនាករយុទ្ធសាស្ត្រគន្លឹះ ក្នុងអំឡុងពេលទាំងបីដំណាក់កាល: ការត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់ ការលុបបំបាត់ជំងឺគ្រុនចាញ់បង្កដោយមេរោគហ្វាល់ស៊ីប៉ារ៉ូម និងការលុបបំបាត់ជំងឺគ្រុនចាញ់គ្រប់ទម្រង់នៃមេរោគគ្រុនចាញ់ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**គោលដៅគន្លឹះដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់ក្នុងព្រះរាជាណាចក្រកម្ពុជា**

| សូចនាករ | ទិន្នន័យគោល | | | ត្រៀមលុបបំបាត់ ត្រឹមឆ្នាំ២០១៥ | លុបបំបាត់ហ្វាល់ស៊ីប៉ារ៉ូម ត្រឹមឆ្នាំ២០២០ | លុបបំបាត់ទាំងស្រុង គ្រប់ទម្រង់ ត្រឹមឆ្នាំ២០២៥ |
|---|---|---|---|---|---|---|
| | តម្លៃ | ឆ្នាំ | ប្រភព | | | |
| **អត្រាស្លាប់ដោយសារជំងឺគ្រុនចាញ់:** ករណីស្លាប់ដោយជំងឺគ្រុនចាញ់ប្រចាំឆ្នាំលើប្រជាជន ១០០០០០ នាក់ ដែលបានរាយការណ៍នៅ តាមសេវាសុខាភិបាលសាធារណៈ | 2.05 | 2009 | ប្រព័ន្ធព័ត៌មានសុខាភិបាល | 0.80 | 0 | 0 |
| **ករណីកើតជំងឺគ្រុនចាញ់:** ករណីជំងឺគ្រុន ចាញ់ប្រចាំឆ្នាំលើប្រជាជន ១០០០ នាក់ ដែលបានរាយការណ៍នៅតាមសេវាសុខាភិបាលសាធារណៈ | 6.16 | 2009 | ប្រព័ន្ធព័ត៌មានសុខាភិបាល | 2.00 | 1.05 | 0 |
| ភាគរយនៃខ្នងផ្ទះក្នុងតំបន់ប្រឈមមុខនឹង ជំងឺគ្រុនចាញ់ខ្ពស់នៅក្នុងភូមិគោលដៅ ដែលមានមុងជ្រលក់ថ្នាំយ៉ាងតិច១ ឬទទួលបានការបាញ់ថ្នាំមូសក្នុងរយៈ១២ខែចុងក្រោយ | 42.6% | 2007 | ការអង្កេតអំពីបញ្ហាគ្រុនចាញ់ | 95% | 95% | 95% |
| ចំនួន និងភាគរយនៃមូលដ្ឋានសុខាភិបាល ដែលមិនមានរបាយការណ៍ស្តីពីការដាច់ស្តុកថ្នាំគ្រុនចាញ់ លើសពី១សប្តាហ៍ ក្នុងកំឡុង ៣ខែចុងក្រោយ | 61.5% | 2007 | ការអង្កេតអំពីបញ្ហាគ្រុនចាញ់ | 75% | 95% | 100% |

## ឈ- ការធ្វើអន្តរាគមន៍ជាគន្លឹះ និងដំណើរការ

តារាងខាងក្រោមសង្ខេបពីអន្តរាគមន៍ សកម្មភាពជាគន្លឹះដែលនឹងត្រូវអនុវត្តក្នុងរយៈពេល ១៥ឆ្នាំខាងមុខ (ពីឆ្នាំ២០១១ ទៅ ឆ្នាំ ២០២៥) ដើម្បីសម្រេចបាននូវការលុបបំបាត់ជំងឺគ្រុនចាញ់ក្នុងព្រះរាជាណាចក្រកម្ពុជា។

### អន្តរាគមន៍ចាំបាច់ដែលនឹងត្រូវអនុវត្តក្នុងរយៈពេល ១៥ឆ្នាំខាងមុខ

| ល.រ | សំណុំអន្តរាគមន៍ | ដំណើរការ |
|---|---|---|
| 1 | **ការត្រួតពិនិត្យ កំចាត់ ភ្នាក់ងារចម្លង និងបង្ការជំងឺគ្រុនចាញ់** | ▪ ការកាត់បន្ថយការចម្លងជំងឺគ្រុនចាញ់ តាមរយៈការបែងចែកមុង ក្នុងអត្រាគ្របដណ្តប់ខ្ពស់ និងបាញ់ថ្នាំសម្លាប់មូសតាមតំបន់គោលដៅ<br>▪ ការគ្រប់គ្រងរួមបញ្ចូលគ្នា ភ្នាក់ងារចម្លងជំងឺគ្រុនចាញ់ ដោយមានការតាមដានលើភាពស៊ាំនឹងថ្នាំសម្លាប់មូស<br>▪ ការកំណត់សំគាល់ច្បាស់លាស់ភូមិសាស្ត្រ និងអង្កេតបាណកសាស្ត្រ<br>▪ ការត្រៀមលក្ខណៈ និងឆ្លើយតបជាអន្តរាគមន៍បន្ទាន់ |
| 2 | **ការគ្រប់គ្រងករណីជំងឺ** | ▪ គោលនយោបាយឱសថត្រូវបានផ្លាស់ប្តូរទៅជាៈ<br>◦ ធ្វើការព្យាបាលផ្តាច់ពូជសំរាបមេរោគវីវ៉ាក់<br>◦ ធ្វើការព្យាបាលដោយឱសថផ្សំជាមួយសារជាតិអាតេមីស៊ីនីន និងថ្នាំសម្លាប់ហ្កាម៉េតសម្រាប់មេរោគហ្វាល់ស៊ីប៉ារ៉ូម<br>▪ ការធ្វើរោគវិនិច្ឆ័យបញ្ជាក់ពីករណីជំងឺដោយប្រើមីក្រូទស្សន៍ ឬតេស្តរហ័សឲ្យបាន១០០ភាគរយ<br>▪ ការធ្វើរោគវិនិច្ឆ័យផ្អែកលើរោគសញ្ញាអាចទទួលស្គាល់បានតែក្នុងកាលៈទេសៈចាំបាច់<br>▪ ត្រួតពិនិត្យគុណភាពនៃការធ្វើរោគវិនិច្ឆ័យដោយមីក្រូទស្សន៍<br>▪ ធ្វើការតាមដានទៅលើភាពស៊ាំនៃឱសថគ្រុនចាញ់ |
| 3 | **ការផ្លាស់ប្តូរឥរិយាបថ និង ការប្រាស្រ័យទាក់ទង** | ▪ ធ្វើការអប់រំសុខភាព<br>▪ ធ្វើការទំនាក់ទំនងជាសាធារណៈ<br>▪ ការផ្តល់មតិគាំទ្រ<br>▪ |
| 4 | **ការទប់ស្កាត់ ការលុបបំបាត់** | ▪ ការទទួលយកការធ្វើរោគវិនិច្ឆ័យបានត្រឹមត្រូវ ទូលំទូលាយ<br>▪ ការទទួលយកការព្យាបាលមានប្រសិទ្ធភាព<br>▪ ការពង្រឹងប្រព័ន្ធសុខាភិបាល (ការគ្របដណ្តប់ផ្នែកឯកជន និងសាធារណៈ ការធានាគុណភាព)<br>▪ ការទំនាក់ទំនងយ៉ាងជិតស្និតជាមួយផ្នែកឯកជន<br>▪ ការគ្រប់គ្រងលើការទិញ លក់ឱសថគ្រុនចាញ់ដែលគ្មានវេជ្ជបញ្ជា<br>▪ មានវិធានការម៉ឺងម៉ាត់ចំពោះការហាមឃាត់ព្យាបាលគ្រុនចាញ់ដោយឱសថតែមួយមុខ ឱសថគ្រុនចាញ់ក្លែងក្លាយ និងឱសថដែលគ្មានប្រសិទ្ធភាព<br>▪ មានបុគ្គលិកដែលមានសមត្ថភាពប្រចាំការនៅតាមគ្រឹះស្ថានសេវាសុខភាពនានា<br>▪ អនុវត្តសាកល្បង និងពង្រីកបន្ថែមការផ្តល់ថ្នាំព្យាបាលជំងឺជាសម្ងហភាព (MDA) ឬការពិនិត្យដោះឈាម និងផ្តល់ថ្នាំព្យាបាលជំងឺផ្តោតតាមទីកន្លែងដែលបានជ្រើសរើស(FSAT) |

| | | |
|---|---|---|
| 5 | **ការស្រាវជ្រាវ និងការធ្វើអង្កេត** | ▪ ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអង្កេតតាមដាននៅទូទាំងប្រទេស<br>▪ ធ្វើទំនើបកម្មទិន្នន័យ របាយការណ៍ថ្នាក់ជាតិ<br>▪ ធ្វើអង្កេតស្តីពីជំងឺគ្រុនចាញ់ក្នុងប្រទេសកម្ពុជារៀងរាល់២ឆ្នាំម្តង (សម្រាប់ឆ្នាំ ២០១២ ២០១៤ ២០១៦ ២០១៨ និង ២០២០)<br>▪ ប្រមូលព័ត៌មានស្តីពីទីតាំងភូមិសាស្ត្រឲ្យបានជាក់លាក់<br>▪ បង្ហាញទិន្នន័យអំពីករណីជំងឺ និងភ្នាក់ងារចម្លងដោយផ្អែកលើប្រព័ន្ធ GIS<br>▪ ទិន្នន័យអំពីការត្រៀមលុបបំបាត់ និងលុបបំបាត់<br>▪ ធ្វើការកំណត់បង្ហាញព័ត៌មានពីករណីជំងឺឲ្យបានឆាប់រហ័ស<br>▪ ការវាយតម្លៃដោយឯករាជ្យដើម្បីដឹងថាសម្រេចបាននូវគោលដៅកំណត់<br>▪ ធ្វើប្រតិបត្តិការស្រាវជ្រាវផ្សេងៗ |
| 6 | **ការគ្រប់គ្រងគម្រោងកម្មវិធី** | ▪ ធ្វើការអភិវឌ្ឍន៍ធនធានមនុស្ស<br>▪ ធ្វើការគ្រប់គ្រងផ្នែកលទ្ធកម្ម និងផ្គត់ផ្គង់<br>▪ ចូលរួមក្នុងគំនិតផ្តួចផ្តើមតាមតំបន់<br>▪ រៀបចំច្បាប់បញ្ញត្តិផ្សេងៗ<br>▪ ត្រួតពិនិត្យតាមដាន ចរាចរឱសថ និងការប្រើប្រាស់<br>▪ គោរពតាមគោលការណ៍នៃការតាមដាន និងវាយតម្លៃ<br>▪ ធ្វើសមាហរណកម្មជាមួយកម្មវិធីសុខភាពនានា សម្រាប់ការធ្វើកិច្ចអន្តរាគមន៍<br>▪ ធ្វើការបែកចែកធនធាន ទាំងធនធានហិរញ្ញវត្ថុក្នុងស្រុក និងក្រៅស្រុក<br>▪ ធ្វើការអភិវឌ្ឍកម្មវិធីសម្រាប់ការត្រៀម និងការលុបបំបាត់ជំងឺគ្រុនចាញ់<br>▪ រៀបចំការប្រជុំក្រុមការងារដើម្បីទប់ស្កាត់ និងលុបបំបាត់ជំងឺគ្រុនចាញ់<br>▪ ធ្វើការអភិបាលដល់បុគ្គលិកសុខាភិបាលដែលជាអ្នកអនុវត្តន៍ផ្ទាល់ និងសហគមន៍<br>▪ គាំទ្រ និងដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រយុទ្ធ និងលុបបំបាត់ជំងឺគ្រុនចាញ់<br>▪ ធ្វើកិច្ចសហប្រតិបត្តិការទាំងផ្នែកបច្ចេកទេស និងការអនុវត្ត ដោយរាប់ទាំងការធ្វើទំនាក់ទំនងក្នុងប្រទេស ប្រទេសជិតខាង និងតំបន់ ។ |

## ញ- ក្រុមទទួលផល និងតំបន់គោលដៅសំខាន់ៗ

តារាងខាងក្រោមបង្ហាញអំពីក្រុមទទួលផល និងតំបន់គោលដៅរួមបញ្ចូល ដើម្បីឈានទៅរកដំណាក់កាលត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់ រយៈពេល៥ឆ្នាំដំបូង (២០១១-២០១៥)។

| ក្រុមគោលដៅ នឹងអ្នកទទួលផល | គោលដៅរួមបញ្ចូលឈានទៅរកដំណាក់កាលត្រៀមលុបបំបាត់ជំងឺ (២០១១-២០១៥) |
|---|---|
| ចំនួនភូមិដែលមានអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ | ១ ៥០០ |
| ចំនួនអ្នកស្ម័គ្រចិត្តចល័តព្យាបាលជំងឺគ្រុនចាញ់ភូមិ | ៤៥០ |
| ចំនួនភូមិដែលមានអ្នកស្ម័គ្រចិត្តសម្រាប់ការងារអប់រំសុខភាព | ៣ ២៩៦ |
| ចំនួនប្រជាជនគោលដៅសម្រាប់ចែកមុងជ្រលក់ថ្នាំ ដែលមានប្រសិទ្ធភាពយូរ | ២.៨៥ លាន<br>(ប្រជាជនដែលរស់នៅចំងាយ ២ គ.ម ពីព្រៃ) |
| ចំនួនប្រជាជនគោលដៅសម្រាប់ចែកមុងអង្រឹងជ្រលក់ថ្នាំដែលមានប្រសិទ្ធិភាពយូរ | ៥៣៧ ៤៨៤<br>(ក្នុងចំណោមប្រជាជនរស់នៅចំងាយ២ គ.ម ពីព្រៃ) |
| ចំនួនមណ្ឌលសុខភាពដែលផ្តល់សេវាព្យាបាលរហ័ស | សំដៅលើមណ្ឌលសុខភាព ចំនួន២៧៤ ក្នុងចំណោម ស្រុកប្រតិបត្តិ<br>ដែលមានការរាតត្បាតជំងឺ ចំនួន៤៣ |
| ចំនួនបុស្តិ៍សុខភាពដែលផ្តល់សេវាព្យាបាលរហ័ស | ៨៩ |
| ចំនួនមណ្ឌលសុខភាពដែលផ្តល់សេវាព្យាបាលចំពោះស្ត្រីដែលមានផ្ទៃពោះ | ២៧៤ |
| ចំនួនដងការចាក់ផ្សាយ វីដេអូចល័ត | ៥២២ |
| ចំនួនសេវាសុខាភិបាលឯកជននិងកន្លែងលក់ថ្នាំដែលត្រូវបានពិនិត្យ | ៣ ៧៨០ |
| ចំនួនតេស្តរហ័សដែលបានចែកទៅសេវាសុខាភិបាល ឯកជននិងកន្លែងលក់ថ្នាំនៅតំបន់ដែលមានការ រាតត្បាតដោយជំងឺគ្រុនចាញ់ | ៨៦៩ ៣០០ |
| ចំនួនមន្ទីរពេទ្យដែលបានតាមដានអ្នកជំងឺដែលមានប៉ារ៉ាស៊ីតវិជ្ជមាន នៅថ្ងៃទី៣<br>(តាមដានព្យាបាល) | ៦៥ |
| ចំនួនអ្នកជំងឺគ្រុនចាញ់ដែលបានតាមដានប្រមូល ទិន្នន័យពីផលប៉ះពាល់របស់ថ្នាំគ្រុនចាញ់ | ៧ ៤៤០ |
| ចំនួនបុគ្គលិកសុខាភិបាលសាធារណៈនិងឯកជនដែលបានបណ្តុះបណ្តាលពីការព្យាបាលនិងធ្វើរោគវិនិច្ឆ័យជំងឺគ្រុនចាញ់រហ័សផ្អែកលើមគ្គុទ្ទេសក៍ព្យាបាលថ្មី | សេវាឯកជនៈ ៣ ២០០<br>សេវាសាធារណៈ ២ ៣៥៥<br>សរុបៈ ៥ ៥៥៥ |

## ង- គោលការណ៍ប្រយុទ្ធនឹងជំងឺគ្រុនចាញ់

### បុព្វកថា:

សេវាការពារ និងព្យាបាលជំងឺគ្រុនចាញ់គួរតែផ្តល់ជូនដោយមិនគិតថ្លៃព្រោះថាសេវាហិរញ្ញប្បទានគឺជារនាំងមួយដែលធ្វើឲ្យប្រជាជនក្រីក្រ ប្រជាជនប្រឈមមុខនឹងជំងឺមិនអាចទទួលយកសេវានេះបាន។

### ការធ្វើរោគវិនិច្ឆ័យ:

- រាល់ករណីសង្ស័យជំងឺគ្រុនចាញ់ទាំងអស់ ត្រូវតែទទួលបានការធ្វើរោគវិនិច្ឆ័យមុននឹងព្យាបាលនៅគ្រប់សេវាទាំងអស់ "ធ្វើរោគវិនិច្ឆ័យរួចទើបព្យាបាល"។
- ការធ្វើរោគវិនិច្ឆ័យទាន់ពេលដោយមិនគិតថ្លៃសម្រាប់ការព្យាបាល ត្រូវតែមាននៅគ្រប់សេវាសុខភាពសាធារណៈទាំងអស់ អ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិ អ្នកស្ម័គ្រចិត្តចល័តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ (រួមទាំងកងកម្លាំងយោធា និងកងកម្លាំងនគរបាល)។
- នៅដំណាក់កាលដំបូងនៃការលុបបំបាត់ជំងឺគ្រុនចាញ់ (២០១១-២០១៥): ការធ្វើរោគវិនិច្ឆ័យដោយប្រើតេស្តរហ័ស គឺធ្វើនៅសេវាសុខភាពសាធារណៈ និងអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ។ ការធ្វើរោគវិនិច្ឆ័យដោយប្រើមីក្រូទស្សន៍គឺធ្វើនៅមន្ទីរពេទ្យបង្អែក ឬនៅអតីតមន្ទីរពេទ្យស្រុកចាស់។ ការធ្វើរោគវិនិច្ឆ័យនៅសេវាឯកជន តាមរយៈការលក់តេស្តរហ័សដែលផ្តល់ដោយទីផ្សារសង្គមមានការទទួលស្គាល់។
- នៅដំណាក់កាលនៃការលុបបំបាត់ជំងឺគ្រុនចាញ់ (២០១៦-២០២៥): ត្រូវធ្វើរោគវិនិច្ឆ័យដោយប្រើមីក្រូទស្សន៍ឲ្យបាន ១០០ភាគរយ នៅសេវាសុខភាពសាធារណៈ (រួមទាំងកងកម្លាំងយោធា និងកងកម្លាំងនគរបាល តែមិនរួមបញ្ចូលអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាមភូមិទេ) តែមានករណីលើកលែងខ្លះដូចជា ដាច់ចរន្តអគ្គីសនី សេវានៅពេលយប់ជាដើម។ កម្រិតការធ្វើរោគវិនិច្ឆ័យគ្រុនចាញ់ អនុញ្ញាតចំពោះតែសេវាឯកជន ដែលមានកម្រិតបច្ចេកទេសព្យាបាលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

### ការព្យាបាល:

- រាល់អ្នកផ្តល់សេវាព្យាបាលទាំងអស់ត្រូវតែគោរពតាមមគ្គុទ្ទេសក៍ព្យាបាលជំងឺគ្រុនចាញ់ថ្នាក់ជាតិ។ ការព្យាបាលត្រូវតែផ្តល់ជូនដោយមិនគិតថ្លៃនៅសេវាសុខភាពសាធារណៈទាំងអស់ (ទាំងករណីគ្រុនចាញ់ស្រាល និងធ្ងន់ធ្ងរ) និងនៅក្នុងសហគមន៍ត្រូវផ្តល់សេវាដោយអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់តាមភូមិ អ្នកស្ម័គ្រចិត្តចល័តព្យាបាលជំងឺគ្រុនចាញ់ (ចំពោះតែករណីគ្រុនចាញ់ស្រាល ដោយធ្វើការបញ្ជូនចំពោះករណីគ្រុនចាញ់ធ្ងន់ធ្ងរ)។
- រាល់ករណីគ្រុនចាញ់ទាំងអស់ត្រូវព្យាបាលដោយថ្នាំចម្រុះដែលក្នុងនោះមានសារធាតុអាតេមីស៊ីនី។ ចំពោះករណីគ្រុនចាញ់ដែលបង្កដោយមេរោគហ្វាល់ស៊ីប៉ារ៉ូម ត្រូវព្យាបាលដោយថ្នាំផ្សំឡើងរវាង DHA +Piperaquine រួមជាមួយថ្នាំសម្លាប់ហ្គាម៉ែត Primaquine កម្រិត ៤៥ ម.ក្រ (បើសិនជាមានសុវត្ថិភាព) នៅគ្រប់សេវាសុខាភិបាលសាធារណៈ សេវាឯកជន និងនៅសហគមន៍ទាំងអស់ រួមទាំងកងកម្លាំងយោធា និងកងកម្លាំងនគរបាល។ ចំពោះករណីគ្រុនចាញ់ដែលបង្កដោយមេរោគវីវ៉ាក់ត្រូវព្យាបាលដោយថ្នាំ DHA+Piperaquine រួមជាមួយថ្នាំសម្លាប់ហ្គាមែត Primaquine រយៈពេល ៨ សប្តាហ៍ បើសិនកម្រិត ៥ ម.ក្រ មានសុវត្ថិភាព ឬ៣០ ម.ក្រ ក្នុង១ថ្ងៃ ក្នុងរយៈពេល ១៤ថ្ងៃ ដោយផ្អែកលើតេស្ត G6PD អវិជ្ជមាន។

- ចំពោះសេវាឯកជនៈ ក្នុងដំណាក់កាលដំបូងនៃការលុបបំបាត់ជំងឺគ្រុនចាញ់ (២០១១-២០១៥) ត្រូវហាមការព្យាបាលគ្រុនចាញ់ដោយថ្នាំគ្រុនចាញ់មួយមុខនៅក្នុងសេវាឯកជន។ អនុញ្ញាតឲ្យមានការលក់ថ្នាំគ្រុនចាញ់ប្រភេទថ្នាំ Malarine តាមរយៈគម្រោងទីផ្សារសង្គមមានការទទួលស្គាល់។ នៅពេលដែលគម្រោងមូលនិធិផ្គត់ផ្គង់ឱសថគ្រុនចាញ់ (AMFm) អនុវត្តពេញលេញ ថ្នាំគ្រុនចាញ់ដែលផ្សំជាមួយសារធាតុអាតេមីស៊ីនីន(ACT) នឹងត្រូវបានលក់នៅគ្រប់ទីផ្សារនៅក្នុងប្រទេសកម្ពុជា។
- ក្នុងដំណាក់កាលនៃការលុបបំបាត់ជំងឺគ្រុនចាញ់ (២០១៦-២០២៥) : ត្រូវហាមការលក់ថ្នាំគ្រុនចាញ់គ្រប់ ប្រភេទនៅក្នុងសេវាឯកជន។ ហាមឃាត់ការព្យាបាលជំងឺគ្រុនចាញ់នៅគ្រប់សេវាឯកជនទាំងអស់ លើកលែងតែសេវាឯកជនដែលគោរពទៅតាមលក្ខខណ្ឌរបស់ក្រសួងសុខាភិបាល។

**ការគ្រប់គ្រងភ្នាក់ងារចម្លងៈ**

- នៅសេវាសាធារណៈ ផ្តល់ជូនមុងជ្រលក់ថ្នាំដែលមានប្រសិទ្ធភាពយូរ (ម្នាក់មុងមួយ) និង ផ្តល់ជូនមុងអង្រឹងជ្រលក់ថ្នាំដែលមានប្រសិទ្ធភាពយូរ (មួយគ្រួសារមុងមួយ) ដល់ប្រជាជនភូមិគោលដៅ (ភូមិដែលមានករណីគ្រុនចាញ់) ដោយបន្ថែមការជ្រលក់មុងចាស់ដោយថ្នាំជ្រលក់មុងដែលមានប្រសិទ្ធភាពយូរ។ ធ្វើការបាញ់ថ្នាំនៅកន្លែងដែលមានករណីប៉ារ៉ាស៊ីតវិជ្ជមាននៅថ្ងៃទី៣។
- ចំពោះកងកម្លាំងយោធា និងកម្លាំងនគរបាលៈ ផ្តល់ជូនមុងជ្រលក់ថ្នាំដែលមានប្រសិទ្ធភាពយូរ ឬមុងអង្រឹងជ្រលក់ថ្នាំដែលមានប្រសិទ្ធភាពយូរ (ម្នាក់មុងមួយ) ដោយឥតគិតថ្លៃ។
- ចំពោះប្រជាជនចល័តៈ ផ្តល់ជូនមុងជ្រលក់ថ្នាំដែលមានប្រសិទ្ធភាពយូរ ឬមុងអង្រឹងជ្រលក់ថ្នាំដែលមានប្រសិទ្ធិភាពយូរដោយឥតគិតថ្លៃ ឬឲ្យខ្ចី។
- មធ្យោបាយការពារគ្រុនចាញ់ដ៏ទៃទៀត ដូចជាថ្នាំលាបស្បែកអាចផ្តល់ជូនដោយឥតគិតថ្លៃ អាស្រ័យដោយការសិក្សាស្រាវជ្រាវ។
- ចំពោះសេវាឯកជនៈ ក្នុងដំណាក់កាលដំបូងនៃការលុបបំបាត់ជំងឺគ្រុនចាញ់ (២០១១-២០១៥) យុទ្ធសាស្ត្រ នៃការភ្ជាប់ថ្នាំជ្រលក់មុងជាមួយមុងមុនពេលលក់ចែកចាយដោយអង្គការដៃគូ។

**ការអប់រំផ្លាស់ប្តូរឥរិយាបថៈ**

- ធ្វើការផ្សព្វផ្សាយតាមរយៈ ទូរទស្សន៍ វិទ្យុ វីដេអូ និង ឈុតសំលេងខ្លី ធ្វើការអប់រំជាក្រុមតាមរយៈអ្នកស្ម័គ្រចិត្តភូមិ អ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិ អ្នកស្ម័គ្រចិត្តចល័តព្យាបាលជំងឺគ្រុនចាញ់ភូមិ ក៏ដូចជាតាមរយៈបុគ្គលិកក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារីជាដើម ព្រមទាំងការអប់រំតាមរយៈការប្រាស្រ័យផ្ទាល់ដោយបុគ្គលិកមណ្ឌលសុខភាព។
- ជាពិសេសសង្កត់ធ្ងន់ទៅលើការបណ្តុះបណ្តាលដល់គ្រូបង្រៀន និងការអប់រំសុខភាពដល់សិស្សសាលាដោយមានការសហការណ៍ជាមួយក្រសួងអប់រំ យុវជន និងកីឡា។

**ការតាមដាន និងវាយតម្លៃៈ**

- ក្នុងដំណាក់កាល នៃការលុបបំបាត់ជំងឺគ្រុនចាញ់ (២០១៦-២០២៥) ត្រូវធ្វើការកំណត់ករណីគ្រុនចាញ់ឲ្យបាននៅសេវាសុខភាពឯកជន
- ពង្រឹង និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនូវប្រព័ន្ធព័ត៌មានសុខាភិបាល ក៏ដូចជាប្រព័ន្ធព័ត៌មានគ្រុនចាញ់ និងការតាមដានជំងឺ

- រាល់ព័ត៌មានគ្រុនចាញ់ទាំងអស់ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ។

**ការសហការណ៍ជាមួយសេវាឯកជន:**

- ចលនាជាពិសេសតាមរយៈអង្គការមិនមែនរដ្ឋាភិបាល
- សាកល្បងយុទ្ធសាស្ត្រចម្រុះសេវាសាធារណៈ និងឯកជន ដោយឈានទៅដល់ការពង្រីកជាបណ្តើរៗ
- មានការចូលរួមពីផ្នែកឯកជនជាមួយអ្នកនាំឱសថចូលក៏ដូចជាអ្នកចែកចាយឱសថតាមរយៈគម្រោងAMFm

**ការបណ្តុះបណ្តាលធនធានមនុស្ស:**

- ធានាឲ្យមានបុគ្គលិកសមស្របចាំបាច់នៅគ្រប់ថ្នាក់ដើម្បីឲ្យការអនុវត្តយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់បានជោគជ័យ
- បុគ្គលិកសុខាភិបាលដែលចូលរួមក្នុងការព្យាបាលនិងការការពារជំងឺគ្រុនចាញ់ត្រូវតែមានការលើកទឹកចិត្ត ដូចជាផ្តល់ការបំពាក់បំប៉នលើកកំពស់សមត្ថភាព ការតាមដាន ការផ្តល់ជំបូន្មាន ផ្តល់ឱកាសការងារ ក៏ដូចជាប្រាក់កំរៃលើកទឹកចិត្តបន្ថែម។

## ថ- ការខិតខំប្រឹងប្រែងជាអន្តរវិស័យ

សកម្មភាពទាំងអស់ដែលបានពណ៌នានៅក្នុងយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់នេះ នឹងសម្រេចបានតាមរយៈការខិតខំព្រួតដៃគ្នា សហការជាអន្តរវិស័យ ទាញយកចំណុចខ្លាំងពីដៃគូនិមួយៗ ដើម្បីធ្វើឲ្យសម្រេចបានជាអតិបរមានូវលទ្ធផលនៃយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់ ក៏ដូចជាការពង្រឹងប្រព័ន្ធសុខាភិបាលជារួម។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងធ្វើជាប្រធានដឹកនាំក្រុមការងារថ្នាក់ខេត្ត ស្រុក ក្នុងការអនុវត្តយុទ្ធសាស្ត្រនៃការលុបបំបាត់ជំងឺគ្រុនចាញ់នេះយ៉ាងមានប្រសិទ្ធភាព។

## ឌ- តួនាទីរបស់ស្ថាប័នឯកជន

ផ្នែកឯកជនដើរតួយ៉ាងសំខាន់នៅក្នុងការធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺគ្រុនចាញ់ដែលមានលក្ខណៈស្រាល។ តាមរយៈរបាយការណ៍ការអង្កេតក្នុងឆ្នាំ២០០៧ មានអ្នកឆ្លើយសំណួរប្រមាណជា ២ភាគ ៣ រាយ-ការណ៍ថាពួកគាត់ស្វែងរកការព្យាបាលជំងឺគ្រុនចាញ់នៅក្នុងស្ថាប័នឯកជន។ ដោយកត់សំគាល់ឃើញដូចនេះ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ (CNM) កំពុងប្រតិបត្តិនូវអន្តរាគមន៍សំខាន់ៗមួយចំនួនដែលមានការសហការពីស្ថាប័នឯកជនក្នុងការគ្រប់គ្រង និងការលុបបំបាត់ជំងឺគ្រុនចាញ់ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រជាតិ។ នៅក្នុងពេលវេលាខាងមុខនេះ (ឆ្នាំ២០១១-២០១៥) ផ្នែកឯកជននឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងនិងលុបបំបាត់ជំងឺគ្រុនចាញ់។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ នឹងប្រកាន់យកគោលការណ៍បីសំខាន់ សម្រាប់ ឲ្យផ្នែកឯកជនចូលរួមសហការៈ (១) ពង្រឹងរឹតបន្តឹងបទបញ្ជា និងការអនុវត្តច្បាប់ រួមទាំងការអនុវត្តការហាម ឃាត់ការប្រើប្រាស់ថ្នាំអាតេមីស៊ីនីនតែមួយមុខ និងការលុបបំបាត់ឱសថក្លែងក្លាយ។ (២) បង្កើតនូវគំនិតផ្តួចផ្តើមរួមបញ្ចូលគ្នាឯកជន និងសាធារណៈ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការធ្វើរោគវិនិច្ឆ័យ និងព្យាបាលករណីជំងឺគ្រុនចាញ់ ក្នុងវិស័យឯកជន រួមទាំងការការបញ្ជូនជំងឺសមស្រប និងការធ្វើរបាយការណ៍មកស្ថាប័នរដ្ឋ និង (៣) បង្កើនការទទួលបាននូវថ្នាំព្យាបាលគ្រុនចាញ់ ACTs ដ៏មានប្រសិទ្ធភាពដែលអាចរកបានក្នុងវិស័យឯកជនតាមរយៈ គម្រោង AMFm។

នៅពេលដែលកម្ពុជាធ្វើដំណើរឆ្ពោះទៅដំណាក់កាលលុបបំបាត់ជំងឺគ្រុនចាញ់ វិស័យឯកជនស្របច្បាប់អាចដើរតួដ៏សំខាន់ក្នុងការបញ្ជាក់អះអាងករណីគ្រុនចាញ់ និងតាមដានករណី។ ក្រសួងសុខាភិបាលនឹងផ្តល់សិទ្ធិឲ្យស្ថាប័នឯកជនដែលបំពេញតាមច្បាប់បញ្ញត្តិរបស់ក្រសួងចូលរួមចំណែកក្នុងយុទ្ធនាការលុបបំបាត់ជំងឺគ្រុនចាញ់។

# ៨- ធនធានហិរញ្ញវត្ថុ

## ក- ការប៉ាន់ស្មានតម្រូវការហិរញ្ញវត្ថុ និងការកំណត់សំគាល់នៃគំលាតហិរញ្ញវត្ថុ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ នៃក្រសួងសុខាភិបាលបានធ្វើការប៉ាន់ស្មានជាបឋមមួយនូវតម្រូវការហិរញ្ញវត្ថុសម្រាប់អនុវត្តយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់ក្នុងប្រទេសដោយផ្អែកលើ ៖

១- បន្ទុកនៃជំងឺគ្រុនចាញ់និងការស្លាប់នៅក្នុងប្រទេស

២- អាទិភាពជាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងជំងឺគ្រុនចាញ់នៅក្នុងប្រទេស

៣- សមត្ថភាពស្រូបយកធនធាននៅក្នុងប្រទេស និង

៤- សមត្ថតភាពបច្ចេកទេស និងការគ្រប់គ្រងរបស់ដៃគូផ្សេងៗដែលនឹងមានការពាក់ព័ន្ធ។

## ខ- តារាងសង្ខេបថវិកាតាមជំពូកចំណាយ

| ជំពូកចំណាយ | តម្រូវការសរុប (US $) | មានក្នុងផែនការអនុម័ត (2010-2015) | គំលាតហិរញ្ញវត្ថុ (2011-2025) |
|---|---|---|---|
| 1. ធនធានមនុស្ស | 65,183,350 | 18,797,015 | 46,386,335 |
| 2. ការបណ្តុះបណ្តាល | 43,809,300 | 12,633,350 | 31,175,950 |
| 3. សម្ភារៈ បរិក្ខារពេទ្យ | 178,542,288 | 48,345,434 | 130,196,854 |
| 4. ឱសថ ប្រត្តិករ | 100,375,966 | 5,807,584 | 94,568,382 |
| 5. ការគ្រប់គ្រងលទ្ធកម្ម និងផ្គត់ផ្គង់ | 94,359,327 | 5,459,472 | 88,899,855 |
| 6. ហេដ្ឋារចនាសម្ព័ន្ធ | 12,945,471 | 3,086,848 | 9,858,623 |
| 7. មធ្យោបាយទំនាក់ទំនង | 46,160,471 | 7,312,550 | 38,847,921 |
| 8. ការតាមដាន និងវាយតម្លៃ | 130,210,742 | 11,322,673 | 118,888,069 |
| 9. ការឧបត្ថម្ភគាំទ្រដល់ក្រុមគោលដៅ | 13,443,842 | 4,026,911 | 9,416,931 |
| 10. ផែនការ និងកាងាររដ្ឋបាល | 14,266,156 | 3,401,766 | 10,864,390 |
| 11. ចំណាយការិយាល័យ | 35,565,673 | 5,871,452 | 29,694,221 |
| 12. ចំណាយផ្សេងៗ | 20,456,302 | 5,675,188 | 14,781,114 |
| សរុប | **755,318,888** | **131,740,243** | **623,578,645** |

ការប៉ាន់ស្មានលំអិតអំពីតម្រូវការនេះនឹងត្រូវធ្វើឡើងតាមរយៈការបង្កើតក្រុមការងាររវាង មជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺគ្រុនចាញ់ ជាមួយនិងការចូលរួមពីដៃគូនៅក្នុងកម្មវិធីគ្រប់គ្រងជំងឺគ្រុនចាញ់។ ក្រុមការងារនីមួយៗនឹងបង្ហាញនូវអាទិភាព ហើយនិងតម្រូវការអន្តរាគមន៍នៅតំបន់ផ្សេងៗនៅក្នុងប្រទេស ត្រួតពិនិត្យថាតើដៃគូមួយណាដែលល្អជាងគេបំផុតក្នុងការផ្តល់សេវាកម្មនៅតាមបណ្តាខេត្តជាអាទិភាពនានា ព្រមទាំងធ្វើការប៉ាន់ប្រមាណតម្លៃដោយប្រើប្រាស់តម្លៃឯកតាស្តង់ដារ។

ក្រសួងសុខាភិបាលនឹងខិតខំប្រឹងប្រែង ចលនាប្រមូលធនធានដែលត្រូវការដើម្បីដោះស្រាយការខ្វះខាត ឬគំលាតផ្នែកហិរញ្ញវត្ថុ (ដោយការដកយកនូវធនធានដែលមានស្រាប់ ពីតម្លៃនៃតម្រូវការជាសរុប) ដើម្បីអនុវត្តយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់ តាមរយៈការធ្វើសំណើសុំបន្ថែមច្បាស់លាស់ និងសមស្រប។

# ៩- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រនៃក្រសួងសុខាភិបាលបានបង្កើត និងពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃការគ្រប់គ្រងជំងឺគ្រុនចាញ់ ដែលនឹងត្រូវយកមកប្រើប្រាស់សម្រាប់តាមដានការរីកចំរើនក្នុងការអនុវត្តនូវផែនការយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់។ រូបភាពសំខាន់ៗនៃប្រព័ន្ធតាមដាន និងវាយតម្លៃរួមមានដូចខាងក្រោមៈ

- កម្មវិធីជាតិចាត់ទុកជាអាទិភាព ការប្រមូលទិន្នន័យព័ត៌មាន តាមរយៈវិធីសាស្ត្រផ្សេងៗ។ ការតាមដានជាប្រចាំ ការកំណត់ទិន្នន័យគោល ការអង្កេតជាលក្ខណៈបរិមាណ និងគុណភាពពាក់កណ្តាលអាណត្តិគម្រោង និងចុងបញ្ចប់អាណត្តិគម្រោង គឺជាវិធីសាស្ត្រដ៏មានសារៈសំខាន់នៅក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃការគ្រប់គ្រងជំងឺគ្រុនចាញ់នៅកម្ពុជា ដើម្បីតាមដានត្រួតពិនិត្យមើលការរីកចំរើន ទាញយកមេរៀនសម្រាប់រៀបចំកែសម្រួលឲ្យបានត្រឹមត្រូវនៅពាក់កណ្តាលទី ហើយធានាថានឹងសម្រេចបានតាមគោលដៅជាគន្លឹះ។ សូមពិនិត្យមើលសូចនាករនៅ ក្នុងតារាងខាងក្រោម។
- កម្មវិធីជាតិរួមជាមួយ និងអង្គការជាដៃគូ បានធ្វើកិច្ចសន្យាជាមួយភ្នាក់ងារឯករាជ្យណាមួយឲ្យអនុវត្តការសិក្សា អង្កេតរកទិន្នន័យគោលដោយស្វែងយល់អំពីកម្រិតចំណេះដឹង និងការអនុវត្ត ព្រមទាំងការអង្កេតជាលក្ខណៈខ្វែង (Cross-sectional survey) ដើម្បីកំណត់រកមើលប្រេវ៉ាឡង់អេពីដេមីសាស្ត្រ នៃជំងឺគ្រុនចាញ់នាឆ្នាំ២០០៤ ក៏ដូចជា២០០៧ និង២០១០។ ការអង្កេតដូចគ្នានេះក៏មានក្នុងផែនការសម្រាប់អនុវត្ត នៅឆ្នាំ២០១២ និង២០១៤ ដើម្បីបង្ហាញអំពីលទ្ធផលជាទូទៅនៃកម្មវិធី ដោយប្រើប្រាស់នូវវិធីសាស្ត្រវាយតម្លៃជាច្រើន រួមទាំងលក្ខណៈបរិមាណ និងគុណភាព។ លទ្ធផលនៃការវាយតម្លៃនឹងត្រូវបានចែករំលែកជាមួយផ្នែកពាក់ព័ន្ធទាំងអស់នៅថ្នាក់ខេត្ត និងថ្នាក់ជាតិក្នុងប្រទេស និងជាមួយដៃគូអភិវឌ្ឍន៍ ក៏ដូចជាអង្គការ ស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្រនានា។ លទ្ធផលនឹងផ្តល់មកនូវមេរៀនអំពីការអនុវត្ត ហើយនឹងដឹកនាំចង្អុលផ្លូវល្អៗសម្រាប់ធ្វើអន្តរាគមន៍ក្នុងពេលអនាគត ធានានូវការសម្រេចបានតាមទិសដៅ និងគោលបំណងនៃផែនការយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់។
- ការត្រួតពិនិត្យដែលមានលក្ខណៈបន្តប្រចាំ តាមរយៈការអនុវត្តនូវការអង្កេតសិក្សាអំពីសំណាកប្រចាំឆ្នាំ និងការអភិបាលដោយថ្នាក់ដឹកនាំមជ្ឈមណ្ឌលជាតិ នៅតាមបណ្តាខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ។ វិធីនេះនឹងបង្ហាញឲ្យឃើញអំពីលទ្ធផលជាគុណភាពនៃ

អន្តរាគមន៍ នានា ហើយនឹងផ្តល់នូវព័ត៌មានត្រឡប់ទៅថ្នាក់មូលដ្ឋានដែលជាអ្នកប្រតិបត្តិដើម្បីកែលំអស្វែងរកការរីកចំរើន។

- ប្រព័ន្ធព័ត៌មានសុខាភិបាល និងទិន្នន័យអង្កេតតាមដានក្នុងសហគមន៍ តាមរយៈគម្រោងនៃអ្នកស្ម័គ្រចិត្តភូមិព្យាបាលជំងឺគ្រុនចាញ់ នឹងកំណត់អំពីលទ្ធផលដោយ បង្ហាញជាប្រេវ៉ាឡង់នៃជំងឺគ្រុនចាញ់នៅតាមបណ្តាខេត្តផ្សេងៗ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ធ្វើ របាយការណ៍ទៅនាយកដ្ឋានផែនការ និងប្រព័ន្ធព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាលរៀងរាល់ត្រីមាស នូវសូចនាករប្រសិទ្ធភាព និងការគ្របដណ្តប់នៃអន្តរាគមន៍ដែលបានកំណត់។ សូចនាករសំខាន់ៗរួមមានអត្រាឈឺ អត្រាស្លាប់ធៀបនឹងជំងឺទូទៅ អត្រាស្លាប់ក្នុងចំណោមអ្នកជំងឺគ្រុនចាញ់ ដែលសុទ្ធសឹងជាសូចនាករត្រូវបានពិនិត្យរួមគ្នានៅក្នុងក្របខណ្ឌវិស័យសុខាភិបាលប្រចាំឆ្នាំ ព្រមទាំងធ្វើបច្ចុប្បន្នភាពបង្ហាញអំពីការរីកចំរើនរបស់ប្រទេសឆ្លើយតបទៅនឹងគោលដៅសហសវត្សរ៍តាមដំណាក់កាលវេលានិមួយៗ។
- កម្មវិធីជាតិនឹងដំណើរការផងដែរជាភ្នាក់ងារដែលប្រមូលចងក្រងនូវទិន្នន័យសំខាន់ៗ ក្នុងនាមជាអ្នកទទួលជំនួយបន្តពីមូលនិធិសកលនូវសូចនាករដូចគ្នានេះដែរ។ របាយការណ៍ផ្សេងៗនឹងត្រូវបានផ្ញើមកកម្មវិធីជាតិជាប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ពីបណ្តាអង្គភាពប្រតិបត្តិទាំងឡាយ សម្រាប់ការត្រួតពិនិត្យ និងតាមដានលើអន្តរាគមន៍ និងសកម្មភាពដែលបាននិងកំពុងអនុវត្ត។

តារាងខាងក្រោម បង្ហាញជូនអំពីសូចនាករគន្លឹះ និងគោលដៅសំខាន់ៗ ដែលត្រូវដាក់បញ្ចូលទៅក្នុងទម្រង់នៃប្រព័ន្ធតាមដាន ហើយនឹងត្រូវប្រើប្រាស់សម្រាប់ការតាមដាន និងវាយតម្លៃលើលទ្ធផលនៃយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំពី២០១១ ដល់ ២០២៥។

## តារាងសូចនាករនៃយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់

| សូចនាករ | ទិន្នន័យគោល | គោលដៅ | | | | | | | | | | | | | | មតិយោបល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2009 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | |
| **អត្រាស្លាប់ដោយជំងឺ:** ករណីស្លាប់ប្រចាំឆ្នាំដោយជំងឺគ្រុនចាញ់សង្ស័យ និងជំងឺគ្រុនចាញ់បញ្ជាក់ច្បាស់រោគវិនិច្ឆ័យក្នុងប្រជាជន ១០០ ០០០នាក់ រាយការណ៍ដោយសេវាសាធារណៈ: | 2.05 | 1.70 | 1.50 | 1.25 | 1.00 | 0.80 | 0.65 | 0.50 | 0.35 | 0.15 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | គោលដៅគឺ មិនឲ្យមានការស្លាប់ដោយគ្រុនចាញ់សោះនៅត្រឹមឆ្នាំ២០២០ |
| **អាំងស៊ីដង់ជំងឺប្រចាំឆ្នាំ** | **6.16** | 5.60 | 4.90 | 4.00 | 2.90 | 2.00 | 1.85 | 1.65 | 1.45 | 1.25 | 1.05 | **0.85** | **0.65** | **0.40** | **0.15** | **0.00** | គោលដៅគឺត្រឹមឆ្នាំ២០២៥ ធ្វើឲ្យអាំងស៊ីដង់គ្រុនចាញ់ធ្លាក់នៅកម្រិតសូន្យ |

| សូចនាករ | ទិន្នន័យគោល | គោលដៅ | | | | | | | | | | | | | | | មតិយោបល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2009 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | |
| ករណីគ្រុនចាញ់ប្រចាំឆ្នាំ ដែលបញ្ជាក់រោគវិនិច្ឆ័យ ក្នុងចំណោម ប្រជាជន ១០០០នាក់ រាយការណ៍ ដោយសេវាសាធារណៈ | 4.18 | 5.04 | 4.51 | 3.80 | 2.76 | 2.00 | 1.85 | 1.65 | 1.45 | 1.25 | 1.05 | 0.85 | 0.65 | 0.40 | 0.15 | 0.00 | គោលដៅគឺត្រឹមឆ្នាំ២០២៥ ធ្វើឲ្យអាំងស៊ីដង់គ្រុនចាញ់ធ្លាក់នៅកម្រិតសូន្យ |
| ចំនួនស្រុកប្រតិបត្តិ (ក្នុងចំណោមចំនួនស្រុកប្រតិបត្តិ សរុប៤៣ដែលមានគ្រុនចាញ់) ដែលឈានរកស្ថានភាពត្រៀមលុបបំបាត់ (អត្រាកញ្ចក់ឈាម ឬឱបស្និក<៥% ឬអត្រាអាំងស៊ីដង់នៃករណីគ្រុនចាញ់បានធ្វើរោគវិនិច្ឆ័យរបស់មេរោគគ្រប់ប្រភេទ <1/1000នៅសេវាសាធារណៈ | 0<br>0% | 8<br>18% | 10<br>23% | 12<br>27% | 14<br>32% | 18<br>42% | 20<br>47% | 22<br>51% | 24<br>56% | 26<br>60% | 28<br>65% | **31**<br>72% | **34**<br>79% | **37**<br>86% | **40**<br>93% | **43**<br>100% | គោលដៅគឺធ្វើឲ្យ អាំងស៊ីដង់គ្រុនចាញ់ ធ្លាក់នៅកម្រិតសូន្យ ក្នុងប្រជាជន ១០០០នាក់ ជាដំណាក់ៗដើម្បីឈានទៅសម្រេចបានគ្រប់ស្រុកប្រតិបត្តិ ដែលមានគ្រុនចាញ់ទាំង៤៣ នៅត្រឹមឆ្នាំ២០២៥ ។ |

| សូចនាករ | ទិន្នន័យគោល | គោលដៅ | | | | | | | | | | | | | | | មតិយោបល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2009 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | |
| ចំនួនស្រុកប្រតិបត្តិ (ក្នុងចំណោមស្រុកប្រតិបត្តិសរុប ៤៣ ដែលមានគ្រុនចាញ់)ដែលឈានរកស្ថានភាពលុបបំបាត់ដោយអត្រាអាំងស៊ីដង់នៃករណីគ្រុនចាញ់បានស្មើសូន្យ | 0<br>0% | 0<br>0% | 0<br>0% | 0<br>0% | 0<br>0% | 7<br>16% | 9<br>21% | 12<br>27% | 14<br>32% | 16<br>38% | 17<br>40% | **24**<br>**56%** | **31**<br>**72%** | **38**<br>**88%** | **41**<br>**95%** | **43**<br>**100%** | គោលដៅគឺកាត់បន្ថយបន្ទុកនៃ ជំងឺគ្រុនចាញ់ ឲ្យទៅដល់អត្រាអាំងស៊ីដង់ សូន្យករណីក្នុងចំណោមប្រជាជន ១០០០ នាក់ នៅគ្រប់ស្រុកប្រតិបត្តិគ្រុនចាញ់ ទាំង ៤៣ នៅឆ្នាំ ២០២៥។ |
| សមាមាត្រនៃហ្វាល់ស៊ីប៉ារ៉ូម វីវ៉ាក់និងប្រភេទគ្រុនចាញ់ផ្សេងទៀតក្នុងចំណោមគ្រុនចាញ់បានបញ្ជាក់រោគវិនិច្ឆ័យនិងព្យាបាលនៅសេវាសាធារណៈ | PF=<br>70%<br>PV=<br>25%<br>Mix=<br>5% | PF=6<br>3%<br>PV=3<br>0%<br>Mix=<br>7% | PF=<br>57%<br>PV=<br>35%<br>Mix=<br>8% | PF=<br>51%<br>PV=<br>40%<br>Mix=<br>9% | PF=<br>45%<br>PV=<br>45%<br>Mix=<br>10% | PF=<br>39%<br>PV=<br>50%<br>Mix=<br>11% | PF=<br>30%<br>PV=<br>58%<br>Mix=<br>12% | PF=<br>21%<br>PV=<br>66%<br>Mix=<br>13% | PF=<br>12%<br>PV=7<br>6%<br>Mix=1<br>2% | PF=<br>3%<br>PV=<br>86%<br>Mix=<br>11% | PF=<br>0%<br>PV=<br>90%<br>Mix=<br>10% | PF=<br>0%<br>PV=<br>90%<br>Mix=<br>10% | PF=<br>0%<br>PV=<br>90%<br>Mix=<br>10% | PF=<br>0%<br>PV=9<br>0%<br>Mix=<br>10% | PF=<br>0%<br>PV=<br>90%<br>Mix=<br>10% | PF=<br>0%<br>PV=<br>0%<br>Mix=<br>0% | គោលដៅគឺធ្វើឲ្យគ្រុនចាញ់បង្ក ដោយហ្វាល់ស៊ីប៉ារ៉ូម មកនៅ ត្រឹមសូន្យនៅឆ្នាំ ២០២០ និង គ្រុនចាញ់បង្កដោយវីវ៉ាក់ មក នៅត្រឹមសូន្យនៅឆ្នាំ ២០២៥ ។ |

| សូចនាករ | ទិន្នន័យគោល | គោលដៅ | | | | | | | | | | | | | | | មតិយោបល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2009 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | |
| ភាគរយនៃខ្នងផ្ទះមានហានិភ័យគ្រុនចាញ់ដែលនៅក្នុងភូមិគោលដៅដែលយ៉ាងហោច ណាស់មានមុងជ្រលក់ថ្នាំមួយ (មុងជ្រលក់ថ្នាំមានប្រសិទ្ធិភាពរយៈយូរ ឬមុងជ្រលក់ថ្នាំធម្មតា) និង ឬចំនួនខ្នងផ្ទះបានបាញ់ថ្នាំក្នុងរយៈពេល ១២ខែចុងក្រោយ | NA | | 85% | | 95% | | 95% | | 95% | | 95% | | 95% | | 95% | | |
| ភាគរយនៃប្រជាជនមានហានិភ័យគ្រុនចាញ់នៅក្នុងភូមិគោលដៅដែលបានដេកក្នុងមុងជ្រលក់ថ្នាំ (មុងជ្រលក់ថ្នាំមានប្រសិទ្ធិភាពរយៈយូរមុង ឬជ្រលក់ថ្នាំធម្មតា) កាលពីយប់មិញ | NA | | 70% | | 85% | | 90% | | 95% | | 95% | | 95% | | 95% | | |

| សូចនាករ | ទិន្ន ន័យ គោល | គោលដៅ | | | | | | | | | | | | | | | មតិយោបល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2009 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | |
| ភាគរយនៃប្រជាជននៅក្នុងភូមិគោលដៅដែលគ្រុនក្ដៅខ្លួន២ សប្ដាហ៍ ហើយបានព្យាបាលថ្នាំគ្រុនចាញ់តាមការណែនាំរបស់កម្មវិធីជាតិក្នុង រយៈពេល២៤ ម៉ោងនៃការចាប់ផ្ដើមគ្រុនក្ដៅ | NA | | 70% | | 80% | | 85% | | 90% | | 95% | | 95% | | 95% | | |
| ចំនួន និងភាគរយនៃកន្លែងផ្ដល់សេវាដែលអាចធ្វើរោគ វិនិច្ឆ័យដោយមីក្រូទស្សន៍ រឺតេស្តរហ័ស | NA | | 80% | | 85% | | 90% | | 100% | | 100% | | 100% | | 100% | | |
| ចំនួននិងភាគរយនៃកន្លែងផ្ដល់សេវាដែលគ្មានរបាយការណ៍ដាច់ស្តុកថ្នាំលើសពីមួយសប្ដាហ៍នៅក្នុងកំឡុងពេលណាមួយនៃរយៈពេល៣ខែចុងក្រោយ | | | 70% | | 75% | | 90% | | 95% | | 95% | | 100% | | 100% | | |

# ១០- សេចក្តីសន្និដ្ឋាន

ទោះបីមានកត្តាខ្លះៗដែលនាំឲ្យមានការលំបាកនិងប្រឈម ក្នុងការឈានទៅរកការលុបបំបាត់គ្រុនចាញ់ទាំងស្រុងនាឆ្នាំ២០២៥ក្តី ក៏មានហេតុផលនិងកត្តាអំណោយផលជាច្រើនដែលនឹងនាំឲ្យព្រះរាជាណាចក្រកម្ពុជាសម្រេចបានជោគជ័យតាមផែនការយុទ្ធសាស្រ្តជាតិដែលបានអនុម័ត។

ផែនការយុទ្ធសាស្រ្តជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១-២០២៥ បានទទួលការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ម្យ៉ាងទៀតផែនការយុទ្ធសាស្រ្តជាតិនេះតម្រូវឲ្យមានការចូលរួម និងគាំទ្រពីគ្រប់ស្ថាប័នជាតិ និងអន្តរជាតិដែលជាកត្តាគន្លឹះក្នុងការកៀងគរធនធាន រួមមានធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ និងបច្ចេកទេសតាមតម្រូវការចាំបាច់ ។

មានកត្តាអំណោយផលជាច្រើនថែមទៀត រួមមានកត្តាសន្តិភាព ស្ថេរភាពនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ច និងការរីកចំរើនខាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងព័ត៌មាន ការផ្លាស់ប្តូរមុខរបរ ការកែលំអបរិស្ថាន ឥរិយាបថរស់នៅ និងជាពិសេសភាពប្រសើរឡើងនៃការទទួលយកបាននូវអន្តរាគមន៍នៃការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់ តាមរយៈការកែលំអនូវសេវាពិនិត្យព្យាបាល និងការបង្ការការចម្លងដោយមានការត្រួតពិនិត្យ និងតាមដានរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្រ្ត និងបាណកសាស្រ្ត នៃក្រសួងសុខាភិបាល និងអង្គភាពក្រោមឱវាទរបស់ក្រសួងសុខាភិបាល និងដៃគូទាំងឡាយ រួមជាមួយនិងការធ្វើវិមជ្ឈការ និងការពង្រីកនូវសកម្មភាពជាគន្លឹះនៃកម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់រហូតដល់តំបន់ជនបទដាច់ស្រយ៉ាលជាកន្លែងដែលហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលនៅមានកំរិត (តាមរយៈបណ្តាញអ្នកស្ម័គ្រព្យាបាលជំងឺគ្រុនចាញ់តាមភូមិ)។

ដូច្នេះ សម្រាប់ព្រះរាជាណាចក្រកម្ពុជាគឺជាពេលវេលាដែលសមស្របបំផុតសម្រាប់ការចាប់ផ្តើមនូវសកម្មភាពដ៏ជាក់លាក់នៅក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់ជាមួយសកលលោក នៅក្នុងក្តីសង្ឃឹមជឿជាក់ថា ផែនការយុទ្ធសាស្រ្តជាតិនេះបង្ហាញនូវផ្លូវដើរត្រឹមត្រូវច្បាស់លាស់ ឆ្លើយតបទៅនឹងចក្ខុវិស័យរបស់ផែនការយុទ្ធសាស្រ្តជាតិលុបបំបាត់ជំងឺគ្រុនចាញ់នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១-២០២៥ គឺប្រទេសកម្ពុជាមួយដែលគ្មានជំងឺគ្រុនចាញ់ចាប់ពីឆ្នាំ២០២៥តទៅ។

# ឧបសម្ព័ន្ធ

## ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ

- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងកិច្ចការនារី
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងព័ត៌មាន
- ក្រសួងបរិស្ថាន
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព
- ឃ្លាំងឱសថកណ្តាល
- កាកបាទក្រហមកម្ពុជា
- អង្គការសុខភាពគ្មានព្រំដែន
- អង្គការដៃគូដើម្បីការអភិវឌ្ឍន៍
- សកលវិទ្យាល័យស្រាវជ្រាវសាជីវកម្ម
- អង្គការសុខភាពប្រជាជនអន្តរជាតិ
- អង្គការប្រយុទ្ធនឹងគ្រុនចាញ់
- អង្គការសុខភាពគ្រួសារអន្តរជាតិ
- វិទ្យុ ប៊ីប៊ីស៊ី
- មណ្ឌលព័ត៌មានស្ត្រីកម្ពុជា
- សមាគមវេជ្ជបណ្ឌិតកម្ពុជា
- វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា
- សមាគមគ្រុនចាញ់កម្ពុជា
- អង្គការសុខភាពពិភពលោក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព

***__ ស្ថាប័នរដ្ឋ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត នឹងត្រូវបានអញ្ជើញចូលរួមបន្ថែមតាមការចាំបាច់។

# លក្ខខណ្ឌចាំបាច់ដើម្បីសម្រេចជោគជ័យក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់

តារាងខាងក្រោម គឺជាការសង្ខេបនូវតម្រូវការចាំបាច់លក្ខខណ្ឌដើម្បីសម្រេចជោគជ័យក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់នៅក្នុងស្ថានភាពប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងអ្វីដែលត្រូវធ្វើក្នុងរយៈពេល១៥ឆ្នាំ ដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់គ្រប់ប្រភេទទាំងអស់ពីក្នុងប្រទេសកម្ពុជា។

## លក្ខខណ្ឌចាំបាច់ត្រូវអនុវត្តន៏ក្នុងរយៈពេល១៥ឆ្នាំខាងមុខ

| លក្ខខណ្ឌចាំបាច់ | ស្ថានភាពប្រទេសកម្ពុជានាពេលបច្ចុប្បន្ន | អ្វីដែលត្រូវធ្វើក្នុងរយៈពេល១៥ឆ្នាំខាងមុខ |
|---|---|---|
| ឆន្ទៈនយោបាយបញ្ជាក់ច្បាស់លាស់ ដើម្បីចាប់ផ្តើមដំណើរការនូវកម្មវិធី | សម្តេចនាយករដ្ឋមន្ត្រីមានចំណាប់អារម្មណ៍ និងបានគាំទ្រគម្រោងយ៉ាងសកម្ម | ការខិតខំប្រឹងប្រែង ការគាំទ្រគួរតែត្រូវបានចង្អុលបង្ហាញ ដើម្បីធានាបាននូវ និរន្តភាពនៃផលប្រយោជន៍ និងឆន្ទៈនយោបាយ |
| ស្ថេរភាពនយោបាយ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រទេសកម្ពុជាមានស្ថេរភាពនយោបាយ និងហិរញ្ញវត្ថុល្អ | ប្រទេសកម្ពុជាបន្តប្រឹងប្រែងដើម្បីសម្រេចបាននូវស្ថេរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ចឲ្យកាន់តែប្រសើរឡើង |
| ភាពចាស់ទុំក្នុងការប្រតិបត្តិការ និងប្រសិទ្ធភាពនៃការគ្រប់គ្រងជំងឺគ្រុនចាញ់ | មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺគ្រុនចាញ់ គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីជាតិដែលបានអនុវត្តកម្មវិធីសុខភាពយូរជាងគេនៅក្នុងប្រទេសកម្ពុជា | ការខិតខំប្រឹងប្រែងលុបបំបាត់ជំងឺគ្រុនចាញ់គួរតែត្រូវបានចាប់ផ្តើមដោយ ធ្វើការសិក្សាឲ្យបានល្អិតល្អន់អំពីលទ្ធភាពបច្ចេកទេស ការអនុវត្ត និង ហិរញ្ញវត្ថុ (រួមទាំងការពិនិត្យ ប្រសិទ្ធភាពតម្លៃ) |
| មានហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពល្អ ត្រឹមត្រូវនៅទូទាំងតំបន់ប្រតិបត្តិការ | ការកែទម្រង់ផ្នែកសុខាភិបាលកំពុងដំណើរការ និងមានការរីកចំរើនច្រើន តែការលំបាកនៅមាននៅឡើយ | ក្រសួងសុខាភិបាលធានាថា ស្រុកប្រតិបត្តិគោលដៅដែលត្រូវធ្វើការលុបបំបាត់ជំងឺគ្រុនចាញ់ក្នុងដំណាក់កាលដំបូងត្រូវបានផ្តល់អាទិភាពខ្ពស់ក្នុងការពង្រីកហេដ្ឋា-រចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ធនធានមនុស្ស |

| | | |
|---|---|---|
| មានការអនុវត្តប្រកបដោយជោគជ័យក្នុងការគ្របដណ្តប់តាមរយៈការស្រាវជ្រាវអេពីដេមីសាស្ត្រ | ការស្រាវជ្រាវអេពីដេមីសាស្ត្រទើបតែចាប់ផ្តើមអនុវត្តនាពេលថ្មីៗ | ចំនួន និងការពង្រីកភូមិសាស្ត្រនៃតំបន់ស្រាវជ្រាវគួរតែត្រូវបានបង្កើន។ ជាងនេះទៅទៀតគឺពង្រីកការស្រាវជ្រាវមេរោគវិជ្ជមាននៅថ្ងៃទី៣ (ហើយប្រសិនជាចាំបាច់ត្រូវមើលឈាមនៅថ្ងៃទី៧ និង ថ្ងៃទី២១) និងធ្វើការស្រាវជ្រាវសកម្ម |
| ភាពដែលអាចរកបាននៃហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសដែលមានប្រសិទ្ធភាពនៅគ្រប់កន្លែងប្រតិបត្តិការទាំងអស់ | ការអភិបាលគ្រុនចាញ់មានធ្វើនៅមន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ ប៉ុន្តែពុំទាន់ក្រុមបាណកសាស្ត្រ នៅថ្នាក់ខេត្តនៅឡើយ | ធនធានគួរត្រូវបានបែងចែកដើម្បីបង្កើតក្រុមបាណកសាស្ត្រនៅថ្នាក់ខេត្ត និង ប៉ុស្តិ៍គ្រុនចាញ់ក្នុងភូមិដែលស្ថិតនៅឆ្ងាយ ជាង៥គ.ម ពីកន្លែងផ្តល់សេវាសុខភាពសាធារណៈ |
| ការចល័តរបស់ប្រជាជនត្រូវមានលក្ខណៈ តិចតួចរវាងតំបន់ដែលមានគ្រុនចាញ់ខ្ពស់ និងតំបន់ដែលមានគ្រុនចាញ់ទាប | ការចល័ត និងការធ្វើចំណាកស្រុកមានកម្រិត ខ្ពស់ហើយបានស្តែងចេញនូវចលនា បំលាស់ទីរបស់ប្រជាជនយ៉ាងក្លៀវក្លាក្នុង រយៈ ប៉ុន្មានឆ្នាំកន្លងមកនៅក្នុងប្រទេសកម្ពុជា | រាល់ការប្រឹងប្រែងទាំងអស់គួរតែត្រូវបានធ្វើដើម្បីតាមដានការមកដល់របស់ក្រុម ប្រជាជនចល័តក្នុងតំបន់គ្រុនចាញ់ និងផ្តល់មុងជ្រលក់ថ្នាំ ការធ្វើរោគវិនិច្ឆ័យ និងព្យាបាលទាន់ពេលវេលាជាមួយ និងការអប់រំសុខភាពផងដែរ |
| វិន័យនៃការគ្រប់គ្រងកម្មវិធី | ការត្រួតពិនិត្យ ការអភិបាល និងការធ្វើសវនកម្មត្រូវបានពង្រឹងនៅគ្រប់កម្រិត | ផែនការខ្នាតតូចនៅថ្នាក់ស្រុកប្រតិបត្តិគួរតែត្រូវបានពង្រីក ដើម្បីធានានូវការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៃសកម្មភាពគ្រុនចាញ់ទាំងស្រុង។ ការត្រួតពិនិត្យ ការអភិបាល និង ការធ្វើសវនកម្មផ្ទៃក្នុងគួរតែត្រូវបានពង្រឹងបន្ថែមទៀត។ ការគាំទ្រយ៉ាង ខ្លាំងក្លាពីអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋានទាំងអស់គួរតែត្រូវបានធានា ។ |